សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royale de Droit et des Sciences Economiques
Royal University of Laws and Economics

## សារណាបញ្ចប់ការសិក្សា

# មន្ត្រីនគរបាលយុត្តិធម៌ (នៅកម្ពុជា)

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **កែវ ជីហ័រ**
លោក **សុខ គីមឡុង**

សាស្ត្រាចារ្យណែនាំ
លោក **ជុំ អ៊ីម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ កែវ ជីហ៉ារ និង ខ្ញុំបាទ សុខ គីមឡុង ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២១ ឆ្នាំសិក្សា ២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត ដល់រូបខ្ញុំទាំងពីរ និងបានខិតខំចិញ្ចឹមបីបាច់ថែរក្សា ការពារ និងអប់រំ ទូន្មានប្រៀនប្រដៅ រូបខ្ញុំបាទទាំងពីរ យ៉ាងយកចិត្តទុកដាក់បំផុត ចាប់តាំងពីចាប់កំណើត រហូតមកដល់បច្ចុប្បន្ន គឺលោកទាំងពីរ ដែលជាអ្នកចាំជួយជំរុញ និងលើកទឹកចិត្ត ពួកយើងខ្ញុំដោយមិនខ្លាចនឿយហត់ ដើម្បីឱ្យកូនៗ ទទួលបាននូវអនាគតមួយដ៏ភ្លឺស្វាង។
- លោកឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លោក លោកស្រីសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានបង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ ដល់និស្សិត។
- សាស្ត្រាចារ្យណែនាំ លោក **ជុំ អ៊ីម** ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ក្នុងការបង្ហាត់បង្ហាញ ណែនាំ និងជួយកែតម្រូវ ក្នុងដំណើរការនៃការសរសេរសារណារបស់ខ្ញុំទាំងពីរ តាំងពីចាប់ផ្តើម រហូតដល់បញ្ចប់ការសរសេរសារណាមួយនេះដោយជោគជ័យ។

ជាចុងក្រោយយើងខ្ញុំទាំងពីរ សូមបួងសួងដល់បារមីនៃវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ឱ្យតាមជួយថែរក្សាអស់លោក លោកស្រី ដែលបានរៀបរាប់ខាងលើ ឱ្យជួបតែ សេចក្តីសុខ ចម្រើន និងទទួលបាននូវជោគជ័យគ្រប់ភារៈកិច្ចទាំងអស់។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល ៤ឆ្នាំកន្លងមក នេះជាពេលវេលាសម្រាប់និស្សិតក្នុងការសរសេរសារណា វាមិនមែនដើម្បីតែបញ្ចប់ថ្នាក់បរិញ្ញាបត្រនោះទេ វាក៏បានផ្ដល់ឱកាសដល់និស្សិតក្នុងការបង្ហាញនូវសមត្ថភាពរបស់ខ្លួនដែលបានសិក្សាកន្លងមកក្នុងនោះក៏មានរូបខ្ញុំទាំងពីរនាក់ផងដែរ។ ក្រោយពីបានពិភាក្សាគ្នា ពួកយើងខ្ញុំក៏បានជ្រើសរើសប្រធានបទ «**មន្ត្រីនគរបាលយុត្តិធម៌**» មកសរសេរជាសារណាដើម្បីបញ្ចប់ការសិក្សាតែម្តង។

គោលបំណងក្នុងការយកប្រធានបទនេះ មកសរសេរជាសារណា គឺដើម្បីធ្វើជាជំនួយមួយផ្នែកដល់អ្នកសិក្សាទាំងឡាយ ជាពិសេសនិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រនេះតែម្តង ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមអំពីប្រធានបទដែលទាក់ទងទៅនឹងមន្ត្រីនគរបាលយុត្តិធម៌នេះ។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាស្នាដៃមួយនេះ នឹងបានចូលរួមក្នុងការពង្រីកចំណេះដឹង បន្ថែមទៅដល់អ្នកសិក្សាទាំងឡាយ តាមរយៈខ្លឹមសារនៃសារណាមួយនេះ និងចង់បង្ហាញទៅកាន់សាធារណៈជន អំពីគោលបំណងនិងការប្ដេជ្ញាចិត្តរបស់ពួកយើង ក្នុងការបម្រើដល់ជាតិមាតុភូមិគ្រប់កាលៈទេសៈ និងបន្តស្ថា និងការពារប្រទេសជាតិឱ្យបានរុងរឿង ដើម្បីបំពេញបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរ ដែលចង់បាននូវភាពយុត្តិធម៌។

ទោះបីជាសារណាមួយនេះ បានកើតឡើងចេញពីការរៀបចំធ្វើឡើងដោយយកចិត្តទុកដាក់របស់ពួកយើងខ្ញុំ យ៉ាងណាក៏ដោយ ក៏ពួកយើងខ្ញុំជឿជាក់ថា អាចនឹងមានភាពចន្លោះប្រហោងមួយចំនួនជាក់ជាមិនខាន។ ហេតុដូច្នេះហើយ យើងខ្ញុំទាំងពីរនាក់ នឹងរង់ចាំទទួលយកនូវមតិនៃការរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលំអរនូវស្នាដៃមួយនេះ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សមាសភាពមន្ត្រីនគរបាលយុត្តិធម៌**

**ផ្នែកទី១៖ មន្ត្រីនគរបាលយុត្តិធម៌** ........ ២

១. ការទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌តាមរយៈការប្រឡង ........ ២

១.១ លក្ខខណ្ឌក្នុងការប្រឡងយកសញ្ញាប័ត្រ ........ ២

១.២ បែបបទនៃការប្រឡងយកសញ្ញាប័ត្រ ........ ៣

២. ការទទួលនីតិសម្បទាតាមរយៈឋានន្តរៈសក្តិ និងមុខងារ ........ ៣

៣. ការធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ៥

៤. ដែនសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ៥

៤.១ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ៥

៤.២ ការពន្លាតសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ៦

**ផ្នែកទី២៖ ភ្នាក់ងារនគរបាលយុត្តិធម៌** ........ ៦

១. ការទទួលលក្ខណៈសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ ........ ៧

២. ការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ........ ៧

៣. បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ........ ៧

**ផ្នែកទី៣៖ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត** ........ ៨

១. ការទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ........ ៨

២. ការធ្វើសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ........ ៨

៣. បេសកកម្មរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ........ ៨

**ជំពូកទី២**

**តួនាទី និងភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌**

**ផ្នែកទី១៖ ការទទួលពាក្យបណ្តឹង** ........ ៩

១. ការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង ........ ១០

២. ការស្វែងរកបទល្មើសដោយខ្លួនឯង ........ ១០

**ផ្នែកទី២៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង** ........ ១០

១. បទល្មើសឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង ........................................ ១០
២. ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង ........................................ ១១
៣. ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង ........................................ ១១
៤. ចិរវេលានៃការស៊ើបអង្កេត ........................................ ១១
៥. ដំណើរការនីតិវិធីស៊ើបអង្កេតបទល្មើសជាក់ស្តែង ........................................ ១២
៦. ការឃាត់ខ្លួន ........................................ ១៦
៧. ការបញ្ជូនខ្លួន ........................................ ២០
**ផ្នែកទី៣៖ ការស៊ើបអង្កេតបឋម** ........................................ ២១
១. បទល្មើសមិនជាក់ស្តែង ........................................ ២១
២. នីតិវិធីការស៊ើបអង្កេតបឋម ........................................ ២២
**ផ្នែកទី៤៖ កំហុសក្នុងការបំពេញមុខងារ** ........................................ ២៤
១. នីតិវិធីខាងវិន័យ ........................................ ២៤
២. ទណ្ឌកម្ម ........................................ ២៥
**សេចក្តីសន្និដ្ឋាន** ........................................ ២៧
**អនុសាសន៍** ........................................ ២៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាទូទៅដើម្បីឱ្យរដ្ឋមួយ អភិវឌ្ឍន៍ទៅមុខបាន ទាល់តែរដ្ឋនោះមានសន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈល្អ ហេតុដូច្នេះហើយទើបអ្នកដឹកនាំរដ្ឋនីមួយៗ ជាពិសេសស្ថាប័ននីតិបញ្ញត្តិ បានខិតខំតាក់តែង និងធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ដើម្បីឱ្យប្រជាពលរដ្ឋគោរពតាម។ ចំណែកឯស្ថាប័ននីតិប្រតិបត្តិវិញ គឺជាអ្នកចាំអនុវត្តនូវ រាល់លិខិតបទដ្ឋានគតិយុត្តទាំងនោះ គឺនៅពេលដែលមានបុគ្គលណាដែលបានបង្ករ ជាបទល្មើស ដែលនាំឱ្យមានអសន្តិសុខក្នុងសង្គម ដូចដែលមានចែងក្នុងច្បាប់ ត្រូវបញ្ជូនបុគ្គលទាំងនោះទៅកាន់ស្ថាប័នតុលាដើម្បីកាត់ទោសទៅតាមផ្លូវច្បាប់។ ប៉ុន្តែដើម្បីឱ្យការអនុវត្តរបស់ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលា ការ ឱ្យកាន់តែមានប្រសិទ្ធភាពនោះ គេក៏បានបង្កើតនូវអង្គភាពមួយ ដែលមានសមត្ថភាពអាចចុះទៅប្រតិបត្តិការនៅកន្លែងកើតហេតុភ្លាមៗនោះ គឺមន្ត្រីនគរបាលយុត្តិធម៌។

អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ពិតជាមានសារៈសំខាន់ចំពោះការអនុវត្តច្បាប់ ពីព្រោះមន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ ក្នុងការចុះទៅត្រួតពិនិត្យបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម និងបទល្មើសលហុ កំណត់អត្តសញ្ញាណជនល្មើស និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុងតាងផងដែរ[1]។

គោលបំណងក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះ យើងខ្ញុំទាំងពីរនាក់ គឺចង់ស្វែងយល់ឱ្យកាន់តែច្បាស់អំពីសមាសភាព តួនាទី និងភារៈកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចង់បង្ហាញទៅកាន់ប្រជាពលរដ្ឋគ្រប់រូបឱ្យបានស្គាល់កាន់តែច្បាស់ អំពីមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីឱ្យពួកគាត់បានចូលរួមសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ក្នុងការលុបបំបាត់ អំពើអសន្តិសុខនៅក្នុងសង្គម។

មានសំណួរជាច្រើនបានចោទសួរថា តើមន្ត្រីនគរបាលយុត្តិធម៌គឺជានរណា? តើអ្នកណាខ្លះដែលមាននីតិសម្បទាគ្រប់គ្រាន់សម្រាប់ទទួលបានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌? និងតើមន្ត្រីនគរបាលយុត្តិធម៌មានតួនាទី និងភារៈកិច្ចអ្វីខ្លះ?

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវកន្លងមក យើងខ្ញុំទាំងពីរនាក់ សូមធ្វើការបកស្រាយនូវចម្ងល់ខាងលើនេះ ដោយបែងចែកជាពីរជំពូកធំៗ៖ ជំពូកទី១ សមាសភាពនគរបាលយុត្តិធម៌ និងជំពូលទី២ តួនាទី និងភារៈកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌។

[1] មាត្រា៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# ជំពូកទី១

# សមាសភាពមន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី១៖ សមាសភាពមន្ត្រីនគរបាលយុត្តិធម៌

ចំពោះនគរបាលយុត្តិធម៌ ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាបានបែងចែកជាបីសមាស ភាព គឺមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និង មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យ[2]។ ព្រះរាជអាជ្ញា គឺជាអ្នកដឹកនាំ និងសម្របសម្រួល សកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[3]។ ប៉ុន្តែនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ ចុះអនុវត្តដីកា ចាត់ឱ្យស៊ើបសួរជំនួស គឺស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរវិញម្តង[4]។

## ផ្នែកទី១៖ មន្ត្រីនគរបាលយុត្តិធម៌

មុននឹងចូលទៅកាន់សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ខ្ញុំសូមពន្យល់ពីនិយមន័យរបស់មន្ត្រីនគរបាល យុត្តិធម៌ជាមុន។ ចំពោះពាក្យថាមន្ត្រីនគរបាល គឺជាមន្ត្រីដែលមានតួនាទីថែរក្សាសណ្តាប់ធ្នាប់ក្នុងនគរ ឬប្រទេស។ ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌ គឺជាមន្ត្រីនគរបាលដែលមានតួនាទីថែរក្សាសណ្តាប់ក្នុងប្រទេស ខាងផ្នែកយុត្តិធម៌ ដែលស្ថិតនៅក្រោមចំណុះក្រសួងយុត្តិធម៌។

ការទទួលបានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវបានបែងចែកជាពីររបៀប៖

### ១. ការទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌តាមរយៈការប្រឡង

មុននឹងទទួលបាននីតិសម្បទាគ្រប់គ្រាន់ ក្នុងការមានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវឆ្លងកាត់ការប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

#### ១.១ លក្ខខណ្ឌក្នុងការប្រឡងយកសញ្ញាប័ត្រ

ចំពោះបុគ្គលដែលសិទ្ធិគ្រាប់គ្រាន់ក្នុងការប្រឡងយកសញ្ញាប័ត្ររួមមាន៖

- មន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំរើការងារយ៉ាងតិច ២ឆ្នាំ ក្នុងនគរបាលជាតិ។
- នាយទាហាន នៃកងរាជអាវុធហត្ថ ដែលបានបំរើការងារយ៉ាងតិច២ឆ្នាំ ក្នុងកងរាជអាវុធហត្ថ[5]។

នៅពេលដែលពួកគាត់ បានប្រឡងជាប់ទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ហើយ ពួកគាត់នឹងទទួលបាននីតិសម្បទាពេញលេញជាមន្ត្រីនគរបាលយុត្តិធម៌។

[2] មាត្រា៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[3] មាត្រា៥៨ នៃក្រមនីតិវិធិព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[4] មាត្រា៥៨ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[5] មាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

**១.២ បែបបទនៃការប្រឡងយកសញ្ញាប័ត្រ**

កងកម្លាំងទាំងពីរស្ថាប័នត្រូវឆ្លងកាត់ ការប្រឡងបែបវិជ្ជាជីវៈដែលមានគណៈមេប្រយោគមក ពីស្ថាប័នជំនាញដើម្បីធ្វើការអង្កេតមើលផងដែរ។

**១.២.១ វិញ្ញាសាប្រឡង**

វិញ្ញាសាក្នុងការប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ គឺជាវិញ្ញាសាបែបវិជ្ជាជីវៈដែលមានបីប្រភេទ៖

- ទីមួយ៖ នីតិព្រហ្មទណ្ឌទូទៅ
- ទីពីរ៖ នីតិវិធីព្រហ្មទណ្ឌ
- ទីបី៖ ករណីកិច្ចសាស្ត្រ ដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលតាក់តែងឡើងដោយអង្គការសហប្រជាជាតិ។

ចំពោះរយៈពេលនៃការប្រឡង គឺជាការកំណត់ដោយ គណៈមេប្រយោគនៃការប្រឡងផ្ទាល់។ សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលនេះ ត្រូវចុះហត្ថលេខា និងបោះត្រារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ[6]។

**១.២.២ គណៈមេប្រយោគ**

សម្រាប់គណៈមេប្រយោគនៃការប្រឡង គឺស្ថិតនៅក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញា ឬចៅក្រមអយ្យ ការអមតុលាការកំពូល ដែលទទួលមុខងារនេះ។ ចំណែកឯសមាសភាពរបស់គណៈមេប្រយោគ នៃការប្រឡងទាក់ទងទៅនឹង មន្ត្រីនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ រួមមាន៖

- ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល
- ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- តំណាងពីររូប មកពីក្រសួងពាក់ព័ន្ធរបស់បេក្ខជនដែលត្រូវប្រឡង[7]។

## ២. ការទទួលនីតិសម្បទាតាមរយៈឋានន្តរៈសក្តិ និងមុខងារ

មន្ត្រីរាជការដែលមានឋានៈ និងមុខងារដូចដែលបានរៀបរាប់ខាងក្រោម នឹងទទួលបានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ដោយស្វ័យប្រវត្តិ៖

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

ខ. ប្រធាន និងអនុប្រធាន នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

---

[6] មាត្រា៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[7] មាត្រា៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃ៖

- នាយកដ្ឋាននគរបាលព្រំដែន (សម្រាប់បទល្មើសឆ្លងដែន)
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភ័ណ្ឌ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា៖

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម
- ការិយាល័យជនបរទេស។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាល ស្រុក ខណ្ឌ។

ជ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ។

ឈ. ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ ប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យ គ្រប់គ្រងអាវុធជាតិផ្ទុះ

ញ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ ប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍

ដ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ (សម្រាប់បទល្មើសព្រហ្មទណ្ឌ)

ឋ. មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ រាជធានី ខេត្ត ស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេត បទល្មើសព្រហ្មទណ្ឌ ដែលត្រូវបង្កើតឡើងក្នុងករណីចាំបាច់[8]។

ណ. នាយកនគរបាលជាតិ ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្ដីពី «**មន្ត្រីនគរបាលយុត្តិធម៌**» និងនាយទាហាននៃកងរាជអាវុធហត្ថ ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្ដីពី «**មន្ត្រីប៉ូលីសតុលាការ**» មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះចូលជាធរមាន ត្រូវទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ដោយស្វ័យប្រវត្តិ ហើយនឹងត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌[9]។

ចំពោះរដ្ឋមន្ត្រីជាអាណាព្យាបាល នៃមន្ត្រីនគរបាល ឬនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលលើកឡើងនៅក្នុងចំណុច ១.១ និង ២ នៃសារណានេះ ជាអ្នកមានភារៈកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថ ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ តាមរយៈប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិ ធម៌[10]។

### ៣. ការធ្វើសច្ចាររបស់មន្ត្រីនគរបាលយុត្តិធម៌

មុនពេលដែលមន្ត្រីនគរបាលយុត្តិធម៌ អាចបំពេញមុខងារជានគរបាលយុត្តិធម៌បាន បន្ទាប់ទទួលប្រកាសអន្តរក្រសួងស្ដីពីការតែងតាំងហើយ ត្រូវធ្វើសច្ចាជាមុនសិន។ ដោយការធ្វើសច្ចានេះ នឹងធ្វើឡើងនៅមុខសាលាឧទ្ធរណ៍។ រូបមន្តនៃការធ្វើសច្ចាត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌[11]។

### ៤. ដែនសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

ការកំណត់ពីដែនសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺជាកំណត់នូវទំហំនៃការទទួលខុសត្រូវរបស់មន្ត្រីនគរបាលយុត្តិធម៌។

#### ៤.១ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានកំណត់សមត្ថកិច្ចនៅតែក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួន ត្រូវបានចាត់ទៅបម្រើការងារ។ ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ម្នាក់ ត្រូវបានចាត់ទៅបំពេញមុខងារនៅរាជធានីភ្នំពេញ ដូច្នេះគាត់មានសមត្ថកិច្ចនៅតែក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ។ ចំពោះមណ្ឌលរដ្ឋបាលដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវមកបំពេញការងារ ត្រូវកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្ដីពីការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ជាមុន[12]។

---

[8] មាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[9] របាយការបញ្ចប់ការសិក្សារបស់និស្សិត ឃុន ចាន់នឿន ស្ដីពីមន្ត្រីនគរបាលយុត្តិធម៌ ឆ្នាំ២០២០ ទំព័រ៧

[10] មាត្រា៦០ កថាខណ្ឌ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[11] មាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[12] មាត្រា៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ក្នុងករណីការធ្វើប្រតិបត្តិនៅក្រោមមណ្ឌលរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការសុំជំនួយ ពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចដែនដី[13]។

### ៤.២ ការពន្លាតសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ ក៏អាចអនុវត្តមុខងារហួសពីដែនសមត្ថកិច្ចរបស់ខ្លួនបានដែរ ក្នុងករណីដែលមានការអនុញ្ញាតពី៖

- ព្រះរាជអាជ្ញា
- ចៅក្រមស៊ើបសួរ។

#### ៤.២.១ ការអនុញ្ញាតពីព្រះរាជអាជ្ញា

ក្នុងករណីបន្ទាន់ក្នុងការចាប់ខ្លួនជនល្មើស ដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ព្រះរាជអាជ្ញា អាចធ្វើការអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើប្រតិបត្តិការនៅលើវិសាលភាពពេញដែនដី នៃព្រះរាជាណាចក្រកម្ពុជា។ ការអនុញ្ញាតនេះអាចធ្វើដោយផ្ទាល់មាត់បាន ប៉ុន្តែត្រូវចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត[14]។

#### ៤.២.២ ការអនុញ្ញាតពីចៅក្រមស៊ើបសួរ

នៅក្នុងក្របខ័ណ្ឌ នៃការស៊ើបសួរ ចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងករណីបន្ទាន់ គាត់ក៏អាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើប្រតិបត្តិការនៅលើវិសាលភាពលើដែនដី នៃព្រះរាជាណាចក្រកម្ពុជាទាំង មូល[15]។ ចំពោះចៅក្រមដែលបានអនុញ្ញាតឱ្យមានការពន្លាតសមត្ថកិច្ច របស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែជូនព័ត៌ មានទៅដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីតាមគ្រប់មធ្យោបាយ[16]។

ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌មិនបានគោរពតាមវិធាន ដែលបានលើកឡើងនៅក្នុងចំណុច ៤.១ និង ៤.២ នោះទេ រាល់កិច្ចការទាំងឡាយដែលបានបំពេញ ត្រូវទុកជាមោឃៈ[17]។

## ផ្នែកទី២៖ ភ្នាក់ងារនគរបាលយុត្តិធម៌

បន្ទាប់ពីយើងបានសិក្សាអំពីមន្ត្រីនគរបាលយុត្តិធម៌ ឥឡូវយើងចូលមកដល់ភ្នាក់ងារនគរបាលយុត្តិធម៌វិញម្តង។ មានសំណួរមួយចំនួនបានលើកឡើងថា តើមានមន្ត្រីនគរបាលយុត្តិធម៌ហើយ ចាំបាច់មានភ្នាក់ងារនគរបាលយុត្តិធម៌ទៀត? តើភ្នាក់ងារនគរបាលយុត្តិធម៌ ខុសពីមន្ត្រីនគរបាលយុត្តិធម៌យ៉ាងដូចម្តេច? យើងនឹងធ្វើការបកស្រាយនៅខាងក្រោមនេះ៖

[13] មាត្រា៦៨ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[14] មាត្រា៦៨ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[15] មាត្រា៦៨ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[16] មាត្រា៦៨ កថាខណ្ឌ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[17] មាត្រា៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ១. ការទទួលលក្ខណៈសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

អ្នកដែលមានលក្ខណៈសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌គឺ៖

- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត
- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌
- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ[18]។

មិនមែនឱ្យតែបុគ្គលដែលបានរៀបរាប់ខាងលើ សុទ្ធអាចក្លាយជាភ្នាក់ងារនគរបាលយុត្តិធម៌នោះទេ ពួកគាត់ត្រូវបាលជ្រើសរើសតាមប្រកាសអន្តរក្រសួងរវាងក្រសួងសាម៉ី និងក្រសួងយុត្តិធម៌។

### ២. ការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ចំពោះភ្នាក់ងារនគរបាលយុត្តិធម៌ ក៏ត្រូវធ្វើសម្បថដូចមន្ត្រីនគរបាលយុត្តិធម៌ដែរ ប៉ុន្តែការធ្វើសម្បថនេះត្រូវធ្វើនៅមុខសាលាដំបូងរាជធានី ខេត្ត។ រូបមន្តនៃសម្បថ ក៏ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[19]។

### ៣. បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌មានបេសកកម្មសំខាន់ពីរគឺ៖

- ពិនិត្យបទល្មើស ដូចជាបទលហុជាដើម
- ជាជំនួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ

នៅពេលពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍ ប៉ុន្តែរបាយការណ៍នេះ មានតម្លៃត្រឹមតែព័ត៌មានធម្មតាតែប៉ុណ្ណោះ។

ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ មិនអាចបំពេញកិច្ចការទាំងឡាយ ដែលទុកសម្រាប់តែមន្ត្រីនគរបាលយុត្តិធម៌បាលទេ បើមិនដូច្នេះទេ កិច្ចការដែលបានបំពេញនោះត្រូវចាត់ទុកជាមោឃៈ[20]។

នៅពេលដែលភ្នាក់ងារនគរបាលយុត្តិធម៌ មានកំហុសនៅពេលបំពេញមុខងាររបស់ខ្លួន ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បន្ទាប់មកអគ្គព្រះរាជអាជ្ញាត្រូវប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងសាម៉ី ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវទទួលដំណឹងអំពី ចំណាត់ការបន្តនៃនីតិវិធីវិន័យនេះ[21]។

[18] មាត្រា៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[19] មាត្រា៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[20] មាត្រា៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[21] មាត្រា៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

## ផ្នែកទី៣៖ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

នៅក្នុងផ្នែកទី៣ នេះវាជាចំណុចរចនាសម្ព័ន្ធចុងក្រោយរបស់នគរបាលយុត្តិធម៌។ ចំពោះចំណុចមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈនេះ មិនសូវខុសគ្នាទៅនឹងភ្នាក់ងារនគរបាលយុត្តិធម៌ទេ។

### ១. ការទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

ជាមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈទាំងឡាយ ដែលច្បាប់ដោយឡែកដែលពួកគេបម្រើការក្នុងវិស័យនោះ បានប្រគល់អំណាចឱ្យក្នុងការពិនិត្យបទល្មើស ប៉ុន្តែស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា។ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ត្រូវបានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ តាមរយៈប្រកាសរួម រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ[22]។ ក្នុងករណីដែលមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈ ដែលបម្រើការនៅក្នុងក្រសួងកិច្ចការនារី ត្រូវបានតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានផ្តល់នីតិសម្បទាតាមរបស់ប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយនឹងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

### ២. ការធ្វើសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មុននឹងអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ត្រូវធ្វើសម្បថដូចទៅនឹង មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ។ ទីតាំងដែលមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ត្រូវធ្វើសម្បថ គឺនៅមុខសាលាដំបូង ដោយពួកគេត្រូវសម្បថថា នឹងបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់[23]។

### ៣. បេសកកម្មរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត មានភារៈកិច្ចត្រួតពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់ដែលបានផ្តល់ឱ្យពួកគាត់នីតិសម្បទាជាមន្ត្រីនគរបាល និងធ្វើរបាយការណ៍អំពីបទល្មើសប៉ុន្តែរបាយការណ៍នេះមាន តម្លៃត្រឹមតែព័ត៌មានធម្មតាដូចទៅ នឹងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ[24]។

ដូចទៅនឹងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ នៅពេលដែលមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ បានប្រព្រឹត្តកំហុសនៅពេលបំពេញមុខងារ ព្រះរាជអាជ្ញា ឬចៅ ក្រមស៊ើបសួរ ត្រូវជូនដំណឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បន្ទាប់មកអគ្គព្រះរាជអាជ្ញាត្រូវប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងសាមី របស់មន្ត្រីរាជការ ឬភ្នាក់ងារនោះ ដើម្បីចាត់នីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញាក៏ត្រូវដឹងអំពីចំណាត់ការរបស់រដ្ឋមន្ត្រីក្រសួងសាមីទៅលើមន្ត្រី ឬភ្នាក់ងារនោះផងដែរ។ ចំពោះការដាក់ទណ្ឌកម្ម

[22] មាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[23] មាត្រា៨២ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[24] មាត្រា៨២ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ខាងវិន័យនេះ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[25]។

បន្ទាប់ពីបានសិក្សាអំពីសមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌រួច បន្តទៅទៀតយើងខ្ញុំនឹងលើកយកតួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ មកសិក្សាវិញម្តង។

[25] មាត្រា៨៤ កថាខណ្ឌ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# ជំពូក២

# តួនាទី និងភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌

## ជំពូកទី២៖ តួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាល យុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[26]។ មន្ត្រីនគរបាលយុត្តិធម៌ទទួលតែបណ្តឹងទាមទារ និងបណ្តឹងបរិហារតែប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌ពិនិត្យបទល្មើសទាំងឡាយ[27]។

### ផ្នែកទី១៖ ការទទួលពាក្យបណ្តឹង

ការទទួលពាក្យបណ្តឹង ជាសកម្មភាពដំបូងរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលតម្រូវឲ្យមានការធ្វើកំណត់ហេតុ។ ការធ្វើកំណត់ហេតុលើពាក្យបណ្តឹង ត្រូវស្រង់ឲ្យបានត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ការធ្វើកំណត់ហេតុអំពីការដាក់ពាក្យបណ្តឹងត្រូវចុះសេចក្តីដូចតទៅ៖

- ចុះអំពីឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- ចុះអង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលតាំងនៅ
- ចុះអំពីការបរិច្ឆេទឲ្យបានត្រឹមត្រូវ។

រាល់សន្លឹកនៃកំណត់ហេតុ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយដើមបណ្តឹងរដ្ឋប្បវេណី។ មុននឹងចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដើមបណ្តឹងធ្វើការអាននូវកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានខ្លឹមសារកំណត់ហេតុដោយសំឡេងខ្លាំងៗ[28]។

នៅគ្រប់អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ តម្រូវឲ្យមាននូវបញ្ជីបណ្តឹងមួយ សម្រាប់ចុះនូវពាក្យបណ្តឹង។ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងបញ្ជីនូវនិទ្ទេសដូចតទៅ៖

- អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- កាលបរិច្ឆេទនៃការដាក់ពាក្យបណ្តឹង
- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹង
- ប្រភេទ នៃអំពើដែលប្តឹង
- ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេត។

បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ[29]។

---

[26] កថាខណ្ឌ១ មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[27] កថាខណ្ឌ១ មាត្រា៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[28] មាត្រា៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[29] មាត្រា៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ១. ការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង

ការពិនិត្យស្វែងរកបទល្មើស តាមរយៈពាក្យបណ្តឹង គឺសំដៅទៅលើការទទួលបានពាក្យបណ្តឹងដែលបានមកពីប្រជាពលរដ្ឋ ដែលបានប្តឹងមកស្ថាប័នផ្ទាល់។ នៅក្នុងបណ្តឹងមានការបែងចែកជា ពីរ គឺ៖

- បណ្តឹងទាមទា ជាបណ្តឹងរបស់ប្រជាពលរដ្ឋ ឬជនរងគ្រោះ ដែលស្ថិតនៅក្នុងបទល្មើសណាមួយ ហើយគាត់ប្តឹងទៅស្ថាប័នមានសមត្ថកិច្ច គឺប្តឹងទៅនគរបាលយុត្តិធម៌ ដើម្បីទាមទារឲ្យស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយ ឬដំណើរនីតិវិធីទៅលើបណ្តឹងរបស់ដើមបណ្តឹង និងទាមទារនូវសំណងលើការខូចខាត ព្រមទាំងសំណងជម្ងឺចិត្តដែលបានប្រព្រឹត្តលើរូបគាត់។
- បណ្តឹងបរិហារ ជាបណ្តឹងវែកមុខបទល្មើស ដែលមានន័យថា បង្ហាញ ឬក៏បកអាក្រាតនូវបទល្មើស ដើម្បីឲ្យស្ថាប័នមានសមត្ថកិច្ច ដែលគាត់មានសិទ្ធិក្នុងការត្រួតពិនិត្យ និងស្វែងរកភស្តុតាង នៅក្នុងបទល្មើស ដើម្បីចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់។ ក្នុងករណីមួយចំនួន បណ្តឹងបរិហារ អាចធ្វើឡើងបានដោយតតិយជន ដែលស្ថិតក្នុងហេតុការណ៍ផ្ទាល់ និងដឹងពីដំណើររឿងច្បាស់លាស់ ដើម្បីប្តឹងបរិហារទៅមន្ត្រីនគរបាលយុត្តិដែលមានសមត្ថកិច្ច បំពេញកិច្ចការតាមរយៈបណ្តឹងដែលគាត់បានប្តឹង។ ក្នុងករណីមួយចំនួនទៀត បណ្តឹងបរិហារ ក៏អាចធ្វើឡើងបានដោយអាជ្ញាធរសាធារណៈ ដូចដែលបានបញ្ញត្តិនៅក្នុងមាត្រា៤២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

### ២. ការស្វែងរកបទល្មើសដោយខ្លួនឯង

ការពិនិត្យស្វែងរកបទល្មើសដោយខ្លួនឯង គឺមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើឡើងបាន កាលបើបទល្មើសនោះ ជាបទល្មើសជាក់ស្តែង ហើយមន្ត្រីនគរបាលយុត្តិធម៌នោះ បានស្ថិតក្នុងហេតុការណ៍ផ្ទាល់ មានសិទ្ធិ និងករណីយកិច្ចបំពេញមុខងារដោយខ្លួនឯង ដោយមិនចាំបាច់មានការប្តឹងពីប្រជាពលរដ្ឋនោះទេ។

## ផ្នែកទី២៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិក្នុងការបើកការស៊ើបអង្កេតជាក់ស្តែង លុះត្រាតែបទល្មើសដែលបានកើតឡើងនោះ ជាបទល្មើសជាក់ស្តែង។ ហើយការស៊ើបអង្កេតបទល្មើសជាក់ស្តែង មាននូវចំណុចសំខាន់ៗ ជាច្រើន និងដំណើរការលើការស៊ើបអង្កេតជាច្រើនដំណាក់កាល តែដើម្បីបកស្រាយនូវបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌លើការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឲ្យបានស៊ីជម្រៅ ទាល់តែយល់ច្បាស់ពី អ្វីទៅដែលហៅបទល្មើសជាក់ស្តែង?

### ១. បទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

នៅក្នុងមាត្រា៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិពីនិយមន័យអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងថា៖

បទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង៖

- ❖ បទល្មើសដែលកំពុងប្រព្រឹត្ត
- ❖ បទល្មើសដែលប្រព្រឹត្តរួចភ្លាម។

ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងដែរ កាលណានៅក្រោយមានបទល្មើសរួចបន្តិចមក៖

- ❖ ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភីង
- ❖ បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះ បានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។

## ២. ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង

នៅក្នុងមាត្រា៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិពីការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងថា៖

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។

## ៣. ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង

នៅក្នុងមាត្រា៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិពីការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងថា៖

ត្រូវបានចាត់ទុកដូចជាឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់ឧក្រិដ្ឋ ឬបទមជ្ឈឹមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាល យុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

## ៤. ថិរវេលានៃការស៊ើបអង្កេត

ការស៊ើបអង្កេតបទល្មើសជាក់ស្តែងមានថិរវេលាមិនអាចលើសពី៧ (ប្រាំពីរ) ថ្ងៃបានឡើយ ដោយថិរវេលានេះគិតពីថ្ងៃ ប្រព្រឹត្តបទល្មើស។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលា ៧(ប្រាំពីរ) ថ្ងៃនេះ ហើយ

ប្រសិនបើ ការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅ ព្រះរាជអាជ្ញា[30]។

ក្រោយការផុតកំណត់ថិរវេលានៃការស៊ើបអង្កេត ករណីនេះវានឹងក្លាយជាការស៊ើបអង្កេតបឋម ឬក្នុងក្របខណ្ឌនៃការស៊ើបសួរ។

## ៥. ដំណើរការនីតិវិធីស៊ើបអង្កេតបទល្មើសជាក់ស្តែង

### ៥.១ វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង

នៅក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា។

មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលបានបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលកគ្រប់រូបកុំឲ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។

ប្រសិនបើយល់ឃើញថា មានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំគ្នាស៊ើបអង្កេត។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា៦៨ (ការពន្លាតសមត្ថកិច្ចដែនដី)[31]។

### ៥.២ ការឆែកឆេរ

ការឆែកឆេរ តម្រូវឲ្យត្រូវតែគោរពឲ្យបានតឹងតែងបំផុតទៅលើលក្ខខណ្ឌ និងនីតិវិធីដែលមានបញ្ញត្តិក្នុងមាត្រា ៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងមាត្រា៩១ បានបញ្ញត្តិថា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ ពុំចាំបាច់ទាល់តែមានដីកាពីតុលាការនោះទេ ប៉ុន្តែគាត់ត្រូវមានការអនុញ្ញាតជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ដោយការអនុញ្ញាតអាចធ្វើជាលាយ លក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏បាន។ ដូច្នេះនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដែលការឆែកឆេរ តម្រូវឲ្យពួកគាត់គោរពតាមលក្ខខណ្ឌដូចខាងក្រោមៈ

[30] មាត្រា១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
[31] មាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

❖ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ដែលសាក្សីទាំងពីរ ត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ដែលចុះដឹកនាំប្រតិបត្តិការ នៅកន្លែងកើតហេតុ។ ស្របតាមគោលការណ៍ដែលមានបញ្ញត្តិក្នុងមាត្រា៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់ថា សាក្សី មិនអាចជានគរបាលយុត្តិធម៌ ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះទេ។

❖ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨ (ដប់ប្រាំបី) ល្ងាចឡើយ លើកលែងតែ៖

- ក្នុងករណីដែលមានចែងដោយមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង)ក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្នុងករណីដែលមានចែងដោយមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង)ក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្នុងករណីមានសំរែកស្រែកឲ្យគេជួយពីក្នុងទីកន្លែង
- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកជំហដល់សាធារណៈជន។

**<u>ឧទាហរណ៍</u>**៖ កន្លែងដែលបើកពេលយប់ ដែលរួមមានបនពេស្យា បនល្បែង ឬវង្គសាលរាំកម្សាន្តជាដើម គឺអាចឆែកឆេរបាន ព្រោះគេបើកចំហដល់សាធារណៈជន នៅពេលយប់ខុសពីម៉ោង ៦ព្រឹក ដល់ម៉ោង ៦ល្ងាច ដូចនេះមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរបានដោយមិនចាំបាច់មានការគោរពតាមលក្ខខណ្ឌពេលវេលា នៃការឆែកឆេរក៏បានដែរ។

- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។ ក្នុងករណីនេះ វាស្ថិតនៅក្នុងវិធានពិសេសដែលទាក់ទងជាមួយនឹងបទល្មើសគ្រឿងញៀន ដោយការឆែកឆេរមិនចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌពេលវេលាចាប់ពីម៉ោង ៦ព្រឹក ដល់ ៦ល្ងាច។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលនៅក្នុងនោះមានចុះ៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនោះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

នៅក្នុងការឆែកឆេរក៏មាននូវលក្ខខណ្ឌពិសេសដែលបានបញ្ញត្តិដោយច្បាប់គាំពារលើដល់ វិជ្ជាជីវៈមួយចំនួនដូចជា វិជ្ជាជីវៈមេធាវី និងវិជ្ជាជីវៈសារព័ត៌មាន។ ស្របតាមលក្ខខណ្ឌដែលមានបញ្ញត្តិក្នុងមាត្រា៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ។ ហើយការឆែកឆេរការិយាល័យមេធាវីអាចធ្វើបានតែ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ

ហើយការឆែកឆេរនេះទៀតសោតត្រូវធ្វើនៅចំពោះមុខប្រធាន គណៈមេធាវី ឬប្រតិភូប្រធាន គណៈមេធាវី ឬមេធាវីសាមី។ ក្នុងករណីនេះច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានការពារចំពោះវិជ្ជាជីវៈមេធាវី ដែលមន្ត្រីនគរបាលយុត្តិធម៌ មិនអាចបំពានបានឡើយ។

មួយវិញទៀត ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានគាំពារដល់វិជ្ជាជីវៈសារព័ត៌មានដូចគ្នានឹងវិជ្ជាជីវៈមេធាវីដែរ ដោយការការពារចំពោះវិជ្ជាជីវៈសារព័ត៌មាន ទាំងសារព័ត៌មានសរសេរ ទាំងសារព័ត៌មានសោតទស្សន៍ គឺមានន័យថា មន្ត្រីនគបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរ នៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មាន ដោយឯកឯងបានទេ។ មន្ត្រីនគរបាលយុត្តិអាចធ្វើការឆែកឆេរក្នុងអគារសារព័ត៌មាន សហគ្រាសព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍បាន លុះត្រាណាតែធ្វើនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឲ្យការឆែកឆេរនេះ មានការប៉ះពាល់ ឬរំលោភបំពានដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឲ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។

<u>**ឧទាហរណ៍**</u>៖ប្រសិនបើមានករណី មន្ត្រីនគរបាលយុត្តិធម៌ឆែកឆេរអគារសារព័ត៌មានដោយមិនមានវត្តមាន ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបនោះទេ ក្នុងករណីនេះការឆែកឆេរត្រូវចាត់ទុកជាមោឃៈ បានន័យថា គ្រប់យ៉ាងដែលទទួលបាននៅក្នុងនីតិវិធីនោះ គឺពុំអាចយកជាបានការឡើយ។

### ៥.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង

នៅក្នុងនីតិវិធីនៃការឆែកឆេរ បើសិនជាមន្ត្រីនគរបាលយុត្តិធម៌បានរកឃើញនូវវត្ថុណាមួយដែលគួរឱ្យសង្ស័យ គាត់មានសិទ្ធិអំណាចចាប់យកវត្ថុតាងនោះបាន បន្ទាប់ពីការរកឃើញវត្ថុតាង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរៀបចំវេចខ្ចប់នូវភស្តុតាងនោះទុក នឹងត្រូវបិទស្លាកបោះត្រានៅលើវត្ថុនោះ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានបញ្ញត្តិយ៉ាងលម្អិតទាក់ទងនឹងការចាប់យកវត្ថុតាង ដោយនៅពេលចាប់យកវត្ថុតាងមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តតាមនីតិវិធី ដែលតម្រូវឲ្យបង្ហាញវត្ថុតាងដែលបានចាប់ ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើល និងយកទៅវេចខ្ចប់ ពេលដែលវេចខ្ចប់ហើយ ត្រូវបិទស្លាក និងបោះត្រា ដើម្បីរក្សាថាមិនមានការលួចដូរនោះឡើយ។ ម៉្យាងវិញទៀតក្រោយពេលបញ្ចប់ប្រតិបត្តិការណ៍ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើបញ្ជីសារពើភណ្ឌនៃវត្ថុតាងទាំងឡាយដែលបានចាប់យក ហើយត្រូវភ្ជាប់ជាមួយកំណត់ហេតុនៃការឆែកឆេរមួយទៀត ចំពោះកំណត់ហេតុនៃការឆែកឆេរត្រូវកំណត់ឱ្យបានច្បាស់ អំពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រះរាជអាជ្ញាគាត់ផ្តល់ការអនុញ្ញតឱ្យ រីឯការអនុញ្ញាតអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ កំណត់ហេតុស្តីពីការចាប់យក

នេះត្រូវចុះហត្ថលេខា ដោយនៅក្នុងកន្លែងកើតហេតុមានន័យថា សំដៅជាពិសេសទៅលើអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២រូប ដែល មានវត្តមាន ហើយដាច់ខាតត្រូវតែមានគាត់ចុះហត្ថលេខា ឬផ្តិតម្រាមដៃ[32]។

### ៥.៤ ការត្រួតពិនិត្យលើផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញឱ្យធ្វើការពិនិត្យផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ ទៅលើភស្តុតាងដែលខ្លួនទទួលបាននោះ ដើម្បីឱ្យគាត់អាចតាមស្វែងរកភស្តុតាងបន្តទៀត។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះ នៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ បុគ្គលនេះត្រូវស្បថ តាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដោយភក្តីភាពដល់តុលាការ[33]។

### ៥.៥ ការធ្វើកំណត់ហេតុលើការស្តាប់ចម្លើយ

នៅក្នុងករណីការស៊ើបអង្កេតជាក់ស្តែង ការធ្វើកំណត់ហេតុលើការស្តាប់ចម្លើយ វាស្ថិតនៅក្រោមសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលគាត់អាចកោះហៅ និងនាំបុគ្គលគ្រប់រូប ព្រមទាំងជនដែលសង្ស័យថាចូលរួមក្នុងការប្រព្រឹត្តបទល្មើស មកអង្គភាពរបស់ខ្លួន ដើម្បីស្តាប់ចម្លើយ។ មួយវិញទៀតការស្តាប់ចម្លើយទៀតសោត ត្រូវមានការធ្វើកំណត់ហេតុ។ ការធ្វើកំណត់ហេតុត្រូវដកស្រង់ឲ្យត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់បុគ្គលដែលបានផ្តល់ចម្លើយ។ រាល់សន្លឹកកំណត់ហេតុទាំងអស់ត្រូវមានការចុះហត្ថលេខាផ្ទាល់ ឬស្នាមម្រាមដៃរបស់បុគ្គលដែលបានឆ្លើយនូវចម្លើយនោះ។ មុនធ្វើការចុះហត្ថលេខា បុគ្គលនោះត្រូវអាននូវកំណត់ហេតុឡើងវិញ ថាត្រឹមត្រូវ ឬទេ ទើបចុះហត្ថលេខា។ នៅក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសម្លេងខ្លាំងៗ នូវខ្លឹមសារកំណត់ ហេតុនោះ។ កាលបើបុគ្គលនោះ មិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្នាមម្រាមដៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ បើសិនជាករណីដែលបុគ្គលនោះជាជាតិសាសន៍ដទៃ មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែបាន តែតម្រូវឲ្យអ្នកបកប្រែនោះស្បថស្របតាម ឬសាសនារបស់ខ្លួន ថារាល់ពាក្យសំដីដែលខ្លួនបាននិយាយសុទ្ធតែជាការពិត[34]។

### ៥.៦ បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិកោះហៅបុគ្គល ដែលមានផលប្រយោជន៍មកផ្តល់ព័ត៌មាន ហើយបុគ្គលដែលត្រូវបានកោះហៅត្រូវតែចូលខ្លួន។ ក្នុងករណីដែលជននោះរឹងទទឹងដោយមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិស្នើសុំទៅ ព្រះរាជអាជ្ញាដើម្បីសុំឱ្យចេញបញ្ជាឱ្យចូលខ្លួន ព្រោះបញ្ជាឲ្យចូលខ្លួននេះគឺផ្តល់សិទ្ធ

[32] មាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[33] មាត្រា៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[34] មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

អំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដែលចាំបាច់ត្រូវនាំខ្លួនជននោះចូលមកបំភ្លឺនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ។ ការបញ្ជាឲ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផងដែរ។ មួយវិញទៀតកំណត់ទាំងឡាយណា ដែលមិនគោរពនូវវិធានដូចដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌទេ នឹងនាំឲ្យមានមោឃភាពនូវកំណត់ហេតុរបស់នគរបាលយុត្តិធម៌ក្នុងការស្តាប់ចម្លើយ[35]។

## ៦. ការឃាត់ខ្លួន

ដើម្បីឆ្លើយតបទៅនឹងតំរូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាច ឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ៖

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួន ពីព្រះរាជអាជ្ញា។

ការឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ត្រូវបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា។ ប្រសិនបើមន្ត្រីនគរបាលចង់បានពត៌មានពីបុគ្គលណា ដែលនៅក្នុងកន្លែងកើតហេតុ ហើយគាត់គិតថាអាចធ្វើជាសាក្សីបាននោះ វាអាចធ្វើទៅបាន ប៉ុន្តែបើសិនជាគាត់បានបដិសេធមិន ព្រមផ្តល់ព័ត៌មានោះទេ វានឹងចូលទៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់ចំណុចទីមួយ៖ គាត់ប្រកែកមិនព្រមផ្តល់ព័ត៌មាន និងចំណុចទីពីរ៖ មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា ទើបមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលនោះបាន។ នៅពេលដែលឃាត់ខ្លួនបុគ្គលនោះភ្លាមមន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាមដែរមានន័យថា មិនអាចឃាត់ខ្លួនគេដោយមិនរាយការណ៍ ឬជូនដំណឹងទៅ ព្រះរាជអាជ្ញានោះទេ។

### ៦.១ រយៈពេលនៃការឃាត់ខ្លួន

ទាក់ទិននឹងរយៈពេលនៃការឃាត់ខ្លួននេះ គឺមានថិរវេលាតែ ៤៨ម៉ោងប៉ុណ្ណោះ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះបទឧក្រិដ្ឋ ប្រសិនបើមានតម្រុយដែលបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យាពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យាពេលត្រូវស្នើសុំទៅព្រះរាជអាជ្ញាដែល ត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ដែលមានន័យថា តើមានលក្ខណៈសមស្របដែរ ឬទេ។ ការ

[35] មាត្រា៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

អនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យាពេលនេះជាវិធានពិសេស ហើយការពន្យាពេលមិនអាចលើសពី ២៤ ម៉ោងបានឡើយដោយមិនគិតពិចិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន[36]។

ការឃាត់ខ្លួននេះមានលក្ខណៈខុសៗគ្នា ចំពោះបុគ្គលដែលត្រូវឃាត់ខ្លួន។ ប្រសិនបើបុគ្គលនោះជានីតិជន ដែលមានន័យថាចាប់ពី អាយុ១៨ឆ្នាំ ឡើងទៅ ការឃាត់ខ្លួនត្រូវមានរយៈពេល ៤៨ម៉ោង ហើយបទឧក្រិដ្ឋក្នុងករណីមានតម្រុយបញ្ជាក់ថា មានពិរុទ្ធភាពចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចសុំពន្យារពេលបាន ២៤ម៉ោង។ ផ្ទុយទៅវិញ ប្រសិនជាបុគ្គលនោះជាអនីតិជន ដែលមានន័យថាអាយុក្រោម១៨ ឆ្នាំ មិនអាចធ្វើការពន្យារពេលបានទេ។

### ៦.២ ការឃាត់ខ្លួនចំពោះអនីតិជន

ការឃាត់ខ្លួនចំពោះអនីតិជន ត្រូវបានចែកចេញជា ៣(បី) ប្រភេទ ទៅតាមអាយុរបស់អនីតិជនដែលត្រូវធ្វើការឃាត់ខ្លួន ដែលអាយុទាំងនោះរួមមាន អាយុក្រោម ១៤ឆ្នាំ, ពី១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ និងពី១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ៖

- ❖ ចំពោះអនីតិជនអាយុក្រោម ១៤ឆ្នាំ មិនអាចឃាត់ខ្លួនបានឡើយ។
- ❖ ចំពោះអនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ
  - ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោង ឡើយ ។
  - ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ២៤ម៉ោង ឡើយ ។
- ❖ ចំពោះអនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ
  - ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ៤៨ម៉ោង ឡើយ ។
  - ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោង ឡើយ ។

មួយវិញទៀតមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំពោះការឃាត់ខ្លួនអនីតិជននោះគឺ កាលណាបុគ្គល ដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ[37]។

### ៦.៣ កំណត់ហេតុស្តីពីការឃាត់ខ្លួន

ការឃាត់ខ្លួនតម្រូវឲ្យមានការធ្វើកំណត់ហេតុ ព្រោះថាការឃាត់ខ្លួនមិនមែនចេះធ្វើឡើង ដោយមិនធ្វើកំណត់ហេតុនោះទេ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួន ដល់បុគ្គល

---

[36] មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[37] មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ដែលត្រូវបានឃាត់ខ្លួន ដើម្បីប្រាប់គាត់ឲ្យបានដឹងពីមូលហេតុដែលនាំឲ្យមានការឃាត់ខ្លួនគាត់ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ឲ្យសាមីខ្លួនបានដឹងថា គាត់មានសិទ្ធិពឹងពាក់មេធាវីដើម្បីការពារក្តីរបស់ខ្លួន ដែលនេះជាប្រការមួយដើម្បីជៀសវាងនូវការ រំលោភសិទ្ធិ និងផលប្រយោជន៍ពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ទៅលើប្រជាជន ដែលមិនសូវចេះច្បាប់។ ក្នុងករណីចាំបាច់ដែលជនដែលត្រូវឃាត់ខ្លួនជាជនបរទេស ដែលគាត់មិនអាចស្តាប់យល់ភាសាខ្មែរបាននោះ ដូច្នេះគាត់មានសិទ្ធិសុំឲ្យមានអ្នកបកប្រែភាសា ដើម្បីឱ្យនិយាយ ស្តាប់គ្នាបាន ដែលអ្នកបកប្រែភាសានោះ មិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ឬ អ្នកជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ ដោយមានចុះសេចក្តីដូចតទៅ ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
- ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតស្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុអោយស្តាប់ ។ ប្រសិនបើជននេះប្រកែក មិនព្រមចុះហត្ថលេខាឬផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។ ហើយកំណត់ហេតុនេះត្រូវភ្ជាប់ទៅជាមួយនឹងសំណុំរឿងនេះផង[38]។

### ៦.៤ ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងហួសទៅ ចាប់តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះបុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬអ្នកណាផ្សេងដែលមិនមានទំនាក់ទំនងជាមួយអំពើល្មើស។ មេធាវី ឬជនដែលត្រូវបានជ្រើសរើសត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាការបន្ទាន់។ មេធាវី ឬជនដែលត្រូវបានជ្រើសរើស អាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងពិភាក្សាជាមួយជនដែលត្រូវបានឃាត់ខ្លួន បានរយៈពេលចំនួន ៣០នាទី។ នៅពេលដែលធ្វើការសន្ទនាគ្នា គឺ **ត្រូវធ្វើនៅក្នុងក្របខ័ណ្ឌរក្សាការសំងាត់នៃការសន្ទនា**[39] មានន័យថាមិនអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកដទៃផ្សេងទៀត ទៅលួចស្តាប់ការ

[38] មាត្រា៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
[39] មាត្រា១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

សន្ទនាថាតើពួកគេនិយាយគ្នាអំពីអ្វីនោះទេ។ ក្រោយការសន្ទនាជាមួយមេធាវី ឬជនដែលត្រូវបានជ្រើសរើសអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង[40]។

### ៦.៥ ជំនួយការរបស់គ្រូពេទ្យក្នុងការឃាត់ខ្លួន

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ សុំឲ្យគ្រូពេទ្យពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះ សមស្របនឹងការឃាត់ខ្លួនដែរ ឬទេ។

ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍បន្ទាន់ទៅព្រះរាជអាជ្ញា។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់មកជាមួយសំណុំរឿង។ មន្ត្រីនគរបាលយុត្តិធម៌ ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យសុខភាព។

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌ នៃការឃាត់ខ្លួន[41]។

### ៦.៦ បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងអង្គភាពនីមួយៗរបស់នគរបាល ឬ កងរាជអាវុធហត្ថគឺសំដៅទៅលើនគរបាលយុត្តិធម៌សម្រាប់ទទួលជនដែលត្រូវបានឃាត់ខ្លួន ត្រូវតែមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ ដើម្បីធានាថាគ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីនេះ។ បញ្ជីស្តីពីការឃាត់ខ្លួនមានសេចក្តីដូចតទៅ ៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យធ្វើការឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន ជាយថាហេតុ
- ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ[42]។

### ៦.៧ កំណត់ហេតុសរុបនៃការឃាត់ខ្លួន

ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីកំណត់ហេតុសរុបនៃការឃាត់ខ្លួនមួយ ដើម្បីឱ្យគ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន។ កំណត់ហេតុសរុបនេះត្រូវមានចុះនិទ្ទេសដូចខាងក្រោម៖

[40] មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[41] មាត្រា៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[42] មាត្រា១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា
- បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន
- ថិរវេលានៃការឃាត់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកដែលនៅចន្លោះការស្តាប់ចម្លើយនីមួយៗ
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ។
  កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង[43]។

## ៧. ការបញ្ជូនខ្លួន

ដំណាក់កាល នៃការបញ្ជូនខ្លួន ជាដំណាក់កាលមួយដែល មន្ត្រីនគរបាលយុត្តិធម៌ធ្វើសេចក្តីរាយការណ៍ទៅព្រះរាជអាជ្ញាពីមូលហេតុច្បាស់លាស់ ដើម្បីសម្រេចថាតើត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ឬត្រូវដោះលែងឲ្យមានសិទ្ធិសេរីភាពឡើងវិញ។ មួយវិញទៀត យើងដឹងហើយថារយៈពេលនៃការឃាត់ខ្លួនមានរយៈពេលដល់ ៤៨ម៉ោង ដែលជារយៈពេលដែលច្បាប់បញ្ញត្តិ ហើយបើជាបទឧក្រិដ្ឋដែលយល់ឃើញថាមានតម្រុយអាចពន្យាបាន ២៤ម៉ោង។ ក្នុងរយៈពេលនៃការឃាត់ខ្លួននេះ មិនមែនកំណត់ថាទាល់តែផុត ៤៨ម៉ោងបានបញ្ជូនខ្លួនគេទៅព្រះរាជអាជ្ញានោះទេ។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់តែ ៥ម៉ោង ឬតិចជាងនេះ គាត់បញ្ជូនទៅព្រះរាជអាជ្ញាក៏បានដែរ ព្រោះនៅពេលដែល ផុតរយៈពេលនៃការឃាត់ខ្លួនគាត់ត្រូវតែបញ្ជូនបុគ្គលដែលឃាត់ខ្លួននោះទៅព្រះរាជអាជ្ញាភ្លាមតែម្តង។ ក្នុងន័យនេះមានន័យថាមន្ត្រីនគរបាលយុត្តិធម៌អាចបញ្ជូនខ្លួនបុគ្គលនោះ មុនរយៈពេលកំណត់នៃការឃាត់ខ្លួនបាន។

[43] មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ៧.១ ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះ ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា។ ក្នុងករណីដែលព្រះរាជអាជ្ញាមើលឃើញថាវាមិនមានអ្វីធ្ងន់ធ្ងរទេ ព្រះរាជអាជ្ញាអាចមិនបញ្ជូនខ្លួនជននោះទៅឱ្យចៅក្រមស៊ើបសួរបាន ព្រះរាជអាជ្ញាអាចបន្តនីតិវិធីរបស់គាត់ ដោយដោះលែងបុគ្គលនោះឲ្យត្រឡប់មកផ្ទះដើម្បីមានសេរីភាពដូចឡើងវិញ។ សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា មានន័យថាអាចសម្រេចបញ្ជូនបុគ្គលដែលឃាត់ខ្លួនទៅចៅក្រម ស៊ើបសួរ ឬ ដោះលែងឱ្យមានសេរីភាពឡើងវិញ[44]។

### ៧.២ រយៈពេលនៃការបញ្ជូនខ្លួន

បុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយក ទៅចំពោះមុខព្រះរាជអាជ្ញា ។

ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារ មានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ដូចជាឡានមានបញ្ហា ឡានអស់ សាំង ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន។ នៅក្នុងគ្រប់ករណី ទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះក្នុងកំណត់ហេតុនូវមូលហេតុនៃការយឺតយ៉ាវ ហើយត្រូវប្រគល់ជូនព្រះរាជអាជ្ញា[45]។

## ផ្នែកទី៣៖ ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម ជាតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត នៅក្នុងបទល្មើសមិនជាក់ស្តែង តែត្រូវគោរពនូវនីតិវិធីមួយចំនួនដូចខាងក្រោម៖

### ១. បទល្មើសមិនជាក់ស្តែង

បទល្មើសមិនជាក់ស្តែង វាផ្ទុយទៅនឹងបទល្មើសជាក់ស្តែង មានន័យថាបទល្មើសនោះបានប្រព្រឹត្តរួចដោយបានបន្សល់ទុកនូវភស្តុតាង ដូចជាសាកសព ឬតម្រុយមួយចំនួននៅកន្លែងកើតហេតុ។ ហើយអំណាចនៅក្នុងការស៊ើបអង្កេតបឋមនេះ វាខុសគ្នានឹងអំណាចក្នុងការស៊ើបអង្កេតករណីជាក់ស្តែង ដែលការស៊ើបអង្កេតបឋមមាននីតិវិធីដូចខាងក្រោម៖

---

[44] មាត្រា១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[45] មាត្រា១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

## ២. នីតិវិធីការស៊ើបអង្កេតបឋម

នីតិវិធីនៃការស៊ើបអង្កេតបឋម ជាកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ដែលតម្រូវឲ្យមន្ត្រីនគរបាលយុត្តិធម៌ គោរពតាមនីតិវិធីនៅក្នុងដំណើរការនៃការស៊ើបអង្កេត។

### ២.១ ការបើកការស៊ើបអង្កេតបឋម

ពាក់ព័ន្ធការបើកការស៊ើបអង្កេតបឋម កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈឹម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។ ការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌ ត្រូវគោរពតាមវិធាន នៃបទបញ្ញត្តិក្នុងមាត្រា១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះវិធានដែលត្រូវអនុវត្តនៅក្នុងករណីស៊ើបអង្កេតបឋម ដែលមានចែងមាត្រា១១២ ខាងលើបានបញ្ជាក់យ៉ាងច្បាស់ថា បទប្បញ្ញត្តិនៃមាត្រាមួយចំនួន ដែលមានចែងនៅក្នុងការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែងត្រូវយកមកអនុវត្ត នៅក្នុងការស៊ើបអង្កេតបឋមដែរ។ ចំពោះមាត្រាទាំងនោះរួមមាន ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) ។

### ២.២ ការឆែកឆេរក្នុងការស៊ើបអង្កេតបឋម

កាលណាការស៊ើបអង្កេតបឋមនោះទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។

មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដ ពីអ្នកកាន់កាប់ទីកន្លែង។ ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នក កាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរនោះ ត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា "**អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ** "។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែង អវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែក ឆេរតាមការសុំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ។ ការឆែកឆេរត្រូវ ធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ០២(ពីរ) នាក់។ សាក្សីត្រូវ ចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីមិនអាចជានគរបាល

ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការ ក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរមិនអាចផ្តើមមុន ម៉ោង ៦(ប្រាំមួយ) ព្រឹក និងក្រោយ ម៉ោង ១៨ (ដប់ប្រាំបី) ឡើយ ។ បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនេះត្រូវយកមកអនុវត្ត ក្នុងការចាប់យកវត្ថុតាង[46]។

ក្នុងពេលឆែកឆែកឆេរ បើសិនជាមន្ត្រីនគរបាលយុត្តិធម៌បានរកឃើញនូវវត្ថុណាមួយដែលគួរឲ្យសង្ស័យ គាត់មានសិទ្ធិអំណាចចាប់យកវត្ថុតាងនោះបាន បន្ទាប់ពីការរកឃើញវត្ថុតាង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរៀបចំវេចខ្ចប់នូវភស្តុតាងនោះទុក នឹងត្រូវបិទស្លាកបោះត្រានៅលើវត្ថុនោះ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តតាមនីតិវិធីដែលតម្រូវឲ្យបង្ហាញវត្ថុតាងដែលបានចាប់ ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើល និងយកទៅវេចខ្ចប់ ពេលដែលវេចខ្ចប់ហើយ ត្រូវបិទស្លាក និងបោះត្រា ដើម្បីរក្សាថាមិនមានការលួចដូរនោះឡើយ។ ម្យ៉ាងវិញទៀតក្រោយពេលបញ្ចប់ប្រតិបត្តិការណ៍ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើបញ្ជីសារពើភណ្ឌនៃវត្ថុតាងទាំងឡាយដែលបានចាប់យក ហើយត្រូវភ្ជាប់ជាមួយកំណត់ហេតុនៃការឆែកឆេរមួយទៀត ចំពោះកំណត់ហេតុនៃការឆែកឆេរត្រូវកំណត់ឱ្យបានច្បាស់អំពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រះរាជអាជ្ញាគាត់ផ្តល់ការអនុញ្ញាតឱ្យ រីឯការអនុញ្ញាតអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ កំណត់ហេតុស្តីពីការចាប់យកនេះត្រូវចុះហត្ថលេខា ដោយនៅក្នុងកន្លែងកើតហេតុ មានន័យថាសំដៅជាពិសេសទៅលើអ្នកកាន់កាប់ទីកន្លែងឬសាក្សី២រូប ដែលមានវត្តមានហើយដាច់ខាតត្រូវតែមានគាត់ចុះហត្ថលេខា ឬផ្តិតម្រាមដៃ។

### ២.៣ ការបញ្ជាឲ្យចូលខ្លួនក្នុងការស៊ើបអង្កេតបឋម

ការបញ្ជាឲ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបឋម ដែលអនុវត្តដូចគ្នានឹងការបញ្ជាឲ្យចូលខ្លួនក្នុងករណី នៃការស៊ើបអង្កេតករណីជាក់ស្តែង។

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ។

បុគ្គលដែលកោះហៅត្រូវតែចូលមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឲ្យចូលខ្លួន។ បញ្ជាឲ្យចូលខ្លួននេះ ត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។

បញ្ជាឲ្យចូលខ្លួននេះ អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន[47]។

[46] មាត្រា១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
[47] មាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.៤ កំណត់ហេតុ នៃការស្តាប់ចម្លើយក្នុងការស៊ើបអង្កេតបឋម

រាល់ការស្តាប់ចម្លើយទាំងឡាយដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ តម្រូវជាចាំបាច់ត្រូវតែគោរពតាម មាត្រា១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តិអំពី "**កំណត់ហេតុស្រង់យកចម្លើយនៅក្នុងការស៊ើបអង្កេតបឋម**"។

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានការធ្វើកំណត់ហេតុ។ កំណត់ហេតុត្រូវដកស្រង់ដោយ ត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចហៅអ្នកបកប្រែដែល បានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ ។ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយនោះទេ។

### ២.៥ ការឃាត់ខ្លួនជនសង្ស័យ ក្នុងការស៊ើបអង្កេតបឋម

ការឃាត់ខ្លួនជនសង្ស័យនេះ មានការបញ្ជាក់ដោយ បញ្ញត្តិក្នុងមាត្រា១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋឬបទមជ្ឈិមនោះ បទប្បញ្ញត្តិនៃជំពូកទី ៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្តីពីការបញ្ជូនខ្លួន នៃមាតិកាទី២ ស្តីពីការស៊ើបអង្កេត ករណីជាក់ស្តែងក្នុងគន្ថីទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ត្រូវយកមកអនុវត្ត ហេតុនេះ អត្ថន័យដែលបានបកស្រាយយ៉ាងលំអិតរួចហើយ ដូចមានក្នុងការស៊ើបអង្កេតករណីជាក់ស្តែងខាងលើ ត្រូវយកមកពិភាក្សា ឬធ្វើការសិក្សាដូចគ្នាទាក់ទងនឹងការឃាត់ខ្លួនជនជាប់សង្ស័យក្នុងការស៊ើបអង្កេតបឋម។

## ផ្នែកទី៤៖ កំហុសក្នុងការបំពេញមុខងារ

បន្ទាប់ទទួលបានការតែងតាំងពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ និងក្រោយពីបានធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍រួចមក មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអំណាចស្របច្បាប់នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ដូចដែលបានផ្តល់ឲ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌ។

ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ ប្រព្រឹត្តកំហុសក្នុងពេលបំពេញមុខងាររបស់ខ្លួន ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិទាក់ទិនជាមួយ នឹងនីតិវិធីខាងវិន័យនិងទណ្ឌកម្ម ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលដូចគ្នានេះដែរ។

### ១. នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួនត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី

ក្រសួងការពារជាតិដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ ការជាបន្តនៃនីតិវិធីវិន័យនេះ[48]។

**២. ទណ្ឌកម្ម**

ចំពោះទណ្ឌកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលនឹងត្រូវបែកចែកជាទណ្ឌកម្មខាងវិន័យ និងការហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌។

**២.១. ទណ្ឌកម្មខាងវិន័យ**

ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។

កាលណាមន្ត្រីនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន យុត្តាធិការស៊ើបសួរ ឬជំនុំជម្រះដែលទទួលបន្ទុករឿងនេះ ត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូលទៅឲ្យយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី។

ពាក្យសុំដកសិទ្ធិនេះត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា[49]។

**២.២ ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌**

នៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា សភាពធ្ងន់ធ្ងរនៃកំហុស ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម ៖

១. ហាមឃាត់មិនឱ្យបំពេញមុខងារ ជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើនបំផុត។

២. ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។

មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រានូវសេចក្តីសង្កេតរបស់មន្ត្រីនោះទុក។ ចំណែកសាមីជនអាចរកជំនួយពីមេធាវី ឬពីទីប្រឹក្សាម្នាក់ តាមការជ្រើសរើសរបស់ខ្លួន។

សេចក្តីសម្រេចពីការហាមឃាត់ ត្រូវតែបញ្ជាក់សំអាងហេតុ និងត្រូវផ្តល់ជាដំណឹងដល់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ ។

---

[48] មាត្រា៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[49] មាត្រា៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

សេចក្តីសម្រេចនេះអាចជាកម្មវត្ថុ នៃបណ្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញា។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះអាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់អាចដាក់ពាក្យប្តឹងតវ៉ាដោយមានសំអាងហេតុ តែក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃតែប៉ុណ្ណោះ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចហាមឃាត់នោះ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យប្តឹង។ សេចក្តីសម្រេចនេះ មិនអាចប្តឹងតវ៉ាបានឡើយ។

ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ា មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ឡើយ។ មន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីគរបាលយុត្តិធម៌វិញបាន ប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់នោះ។

កិច្ចទាំងឡាយ ដែលមន្ត្រីនគរបាលយុត្តិធម៌ បានបំពេញដោយបំពានលើសេចក្តីសម្រេចពីការហាមឃាត់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នេះ ត្រូវចាត់ទុកជាមោឃៈ[50]។

[50] មាត្រា៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

មន្ត្រីនគរបាលយុត្តិធម៌ ពិតជាមានតួនាទីសំខាន់ក្នុងការអនុវត្តច្បាប់នៅកម្ពុជា ពីព្រោះពួកគេគឺជាជំនួយមួយផ្នែក របស់ស្ថាប័នតុលាការ ក្នុងការចុះទៅត្រួតពិនិត្យបទល្មើសដោយផ្ទាល់ ដោយមានការដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់ខ្លួន ដោយព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបែងចែកជាបី គឺមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃ ដែលត្រូវបានតែងតាំងដោយច្បាប់ដោយឡែក។ ចំពោះការទទួលបាលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តធម៌ មានពីររបៀបគឺ តាមរយៈការប្រឡង និងតាមរយៈឋានន្តរសក្តិ និងមុខងារ។

មន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ។ នៅក្នុងដំណើរការនៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេត ដោយខ្លួនឯង បន្ទាប់ពីមានតម្រុយខ្លះៗ ឬបានទទួលពាក្យបណ្តឹងពីជនរងគ្រោះ តតិយជន ឬជនអនាមិកដែលបានធ្វើការរាយការណ៍។ ការស៊ើបអង្កេតមានពីររបៀប គឺការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម(ក្នុងករណីបទល្មើសមិនជាក់ស្តែង)។ ក្នុងការធ្វើការស៊ើបអង្កេតក្នុងបទល្មើសនីមួយៗ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែអនុលោមទៅតាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាដាច់ខាត់ ពីព្រោះក្នុងករណីដែលដំណើរការស៊ើបអង្កេត ណាមួយរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមិនបាន អនុលោមទៅតាមច្បាប់នោះ រាល់សកម្មភាពក្នុងការស៊ើបអង្កេត ត្រូវបានច្បាប់ចាត់ទុកជាមោឃៈ។

ចំពោះបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានគោលដៅក្នុងការស្វែងរកជន ដែលបានប្រព្រឹត្តបទល្មើស ដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ និងសង្គមជាតិទាំងមូល។ នៅក្នុងដំណើរការក្នុងការស្វែងរកជនដែលបានប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែអនុវត្តនីតិវិធីដូចដែលច្បាប់បានបញ្ញត្តិ ដូចជាការសាកសួរជនសង្ស័យ និងសាក្សីជាដើម ពីព្រោះវាអាចធ្វើឱ្យមន្ត្រីនគរបាលយុត្តិធម៌ ងាយស្រួលក្នុងកំណត់អត្តសញ្ញាណរបស់ជនដែលបានប្រព្រឹត្តបទល្មើសបានឆាប់រហ័ស។ ក្រៅពីនីតិវិធីក្នុងការសាកសួរ ជនសង្ស័យ និងសាក្សីផ្សេងៗ ការប្រមូលភស្តុតាងដែលបានបន្សល់នៅកន្លែងកើតហេតុ ក៏ជានីតិវិធីសំខាន់ក្នុងការប្រមូលព័តមានគ្រប់គ្រាន់ ក្នុងការកំណត់អត្តសញ្ញាណរបស់ជនសង្ស័យ និងឈានទៅដល់ការចាប់ខ្លួនជនសង្ស័យនោះ តាមរយៈដីការបស់ព្រះរាជអាជ្ញា។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវនៅក្នុងប្រធានបទមន្ត្រីនគរបាលយុត្តធម៌នេះ ពួកខ្ញុំទាំងពីរនាក់ ក៏មាននូវគំនិតយោបល់មួយចំនួន ដើម្បីអាចឱ្យសារណាមួយនេះ បានចូលរួមចំណែក ក្នុងការយកទៅអនុវត្តក្នុងសង្គមជាតិបាននោះ យើងខ្ញុំទាំងពីរសូមធ្វើការផ្តល់អនុសាសន៍ដូចខាងក្រោម៖

- សូមសំណូមពរ ទៅដល់ក្រសួងមានសមត្ថកិច្ច ជាពិសេសក្រសួងយុត្តិធម៌ ធ្វើបង្កើតនូវវគ្គបណ្តោះបណ្តាល អំពីច្បាប់ព្រហ្មទណ្ឌផ្សេងៗ ទៅដល់មន្ត្រីនគរបាលយុត្តិធម៌ ជាពិសេសមន្ត្រីនគរបាលដែលនៅតាមភូមិ ឃុំ នៅតាមបណ្តាលខេត្ត ពីព្រោះតែយើងខ្ញុំបានសង្កេតឃើញថា មន្ត្រីនគរបាលយុត្តធម៌ នៅតាមបណ្តាល ភូមិ ឃុំ នៅតាមខេត្ត មិនទាន់បានយល់ច្បាស់អំពីច្បាប់ព្រហ្មទណ្ឌនៅឡើយ ហេតុដូច្នេះហើយធ្វើឱ្យការអនុវត្តរបស់ពួកគាត់នៅមានចន្លោះខ្វះខាតច្រើន។

- សូមសំណូមពរទៅដល់ប្រជាពលរដ្ឋទាំងអស់ មេត្តាជួយចូលរួមសហការជាមួយនឹង មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការធ្វើការរាយការណ៍ ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលមានបទល្មើសណាមួយកើតឡើង ឬបានដឹងអំពីបទល្មើសនោះ និងចូលរួមសហការក្នុងកិច្ចស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការធ្វើជាសាក្សីជាដើម។

- សូមសំណូមពរទៅកាន់មន្ត្រីនគរបាលយុត្តិធម៌គ្រប់រូប មេត្តាគោរពឱ្យបាននូវក្រមសីលធម៌ និងគោលការណ៍ទាំងឡាយដែលបានបញ្ញត្តិក្នុងច្បាប់ កុំធ្វើការសម្រេចក្នុងកិច្ចការអ្វីមួយឱ្យលើសពីដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីនៅពេលដែលមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង គាត់មិនបានបញ្ជូនសំណុំរឿងទៅថ្នាក់លើទេ បែរជាធ្វើការសម្របសម្រួលរវាងជនរងគ្រោះ និងជនសង្ស័យទៅវិញ ដែលធ្វើឱ្យការអនុវត្តច្បាប់លែងមានប្រសិទ្ធភាព។

- សូមសំណូមពរទៅកាន់មន្ត្រីនគរបាលយុត្តធម៌ទាំងអស់ មេត្តាចូលរួមលុបបំបាត់នូវអំពើពុករលួយនៅក្នុងសង្គម ដែលជារបាំងមួយដ៏ធំក្នុងធ្វើឱ្យសង្គមជាតិឈានទៅរកភាពអយុត្តិធម៌នៅក្នុងសង្គម ដែលធ្វើឱ្យមានភាពអសន្តិសុខក្នុងសង្គមកាន់តែកើនឡើង។

# ឯកសារយោង

# ឯកសារយោង


1. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
2. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
3. របាយការណ៍បញ្ចប់ការសិក្សារបស់និស្សិត យុន ចាន់នឿន ស្តីពី «មន្ត្រីនគរបាលយុត្តិធម៌» ឆ្នាំ២០២០
4. សារណាបញ្ចប់ការសិក្សារបស់និស្សិត វណ្ណា ហង្សពីរ និង អៀវ គានគីងសេង ស្តីពី «មន្ត្រីនគរបាលយុត្តិធម៌ក្នុងនីតិវិធីព្រហ្មទណ្ឌ» ឆ្នាំ២០២០
5. សៀវភៅ «នគរបាលយុត្តិធម៌» រៀបរៀងដោយ លោក ខាន់ សុខា និងលោកស្រី ឌី លីឡា
6. ឯកសារ «ដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់មន្ត្រីអនុវត្តច្បាប់នៅកម្ពុជា» រៀបចំដោយ ក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា
7. https://www.youtube.com/watch?v=5h8W0EzCsHo ( ចូលមើលថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២១ ម៉ោង ១៣៖០០នាទី )
8. https://www.youtube.com/watch?v=T_zK9urvb1M ( ចូលមើលថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២១ ម៉ោង ១៣៖៤៥នាទី )
9. https://youtu.be/N3R9QGvjimg ( ចូលមើលថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ម៉ោង ១៤៖១០នាទី )
10. https://youtu.be/DU-g-_--1d8 ( ចូលមើលថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ម៉ោង ១៥៖០០នាទី )
11. http://www.moj.gov.kh/kh/gallery/06-01-2020_121643pm?video=1 (ចូលមើលថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ម៉ោង ១៣៖២០នាទី)

# ឧបសម្ព័ន្ធ

# ប្រកាស

# ស្តីពី

# បែបបទ និងនីតិវិធី នៃការធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ: ៣៤៤ ក.យ.ប្រក/០៧

រាជធានីភ្នំពេញ. ថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០០៧

# ប្រកាស

## ស្តីពី

## បែបបទ និងទម្រង់ការ នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :**

ត្រូវបានទទួលនូវគុណសម្បត្តិ ជាភ្នាក់ងារនគរបាលយុត្តិធម៌ ចំពោះមន្ត្រីនគរបាល កងរាជអាវុធហត្ថ យោធិន ដែលចាំបាច់ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ :

១- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

២- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត ។

៣- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

៤- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

**ប្រការ ២ :**

មុននឹងបំពេញមុខងារ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូង នៅតាមបែបបទ និងរូបមន្ត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៣ :**

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ប្រការ ៤ :**

ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងគ្រប់ខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

អង្គ វង្សវឌ្ឍនៈ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- តុលាការ និងអយ្យការសាលាដំបូងខេត្ត-ក្រុង
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធនៃប្រកាសលេខ ៣៥ កយ.ប្រក/ ០៧ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧*

# នីតិវិធី

## នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

១- ក្រឡាបញ្ជី ជាអ្នកចាត់តាំងកម្មវិធី :

- ហៅឈ្មោះអ្នកដែលចូលធ្វើសម្បថម្នាក់ម្តង១ ចូលក្នុងសាលពិធី
- ប្រកាសបើកពិធីធ្វើសម្បថ ភ្នាក់ងារនគរបាលយុត្តិធម៌
- ប្រកាសសមាសភាព ក្រុមប្រឹក្សា តំណាងអយ្យការ និងក្រឡាបញ្ជី :

☞ តំណាងតុលាការ

- លោក............................ ប្រធានសាលាដំបូង

☞ តំណាងអយ្យការ

- លោក............................ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង

☞ ក្រឡាបញ្ជី

- លោក............................ ក្រឡាបញ្ជីនៃពិធី

២- ក្រឡាបញ្ជីអានបញ្ជីឈ្មោះអ្នកដែលត្រូវស្បថ

៣- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

៤- តំណាងភ្នាក់ងារនគរបាលយុត្តិធម៌ម្នាក់ អាន **ប្រការសច្ចាប្រណិធាន** ( ឱ្យអ្នកស្បថថាតាមខ្លាំង១ )

៥- ប្រធានក្រុមប្រឹក្សា អាន **សច្ចាប្រណិធាន** ( ឱ្យអ្នកស្បថលើកដៃស្តាំដាក់ត្រឹមត្រចៀក និងថាតាមខ្លាំង១ )

៦- មតិផ្តាំផ្ញើ របស់តំណាងអយ្យការ

៧- មតិផ្តាំផ្ញើ របស់ប្រធានក្រុមប្រឹក្សា

៨- ចប់កម្មវិធី

*__សំគាល់:__ អ្នកស្បថទាំងអស់ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ និងចម្លងកំណត់ហេតុជូនសាមីខ្លួនម្នាក់១*

## ប្រណិធាន (សេចក្តីអំពាវនាវ)

បពិត្រអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មាន : ព្រះអង្គដង្កើរ ព្រះអង្គក្រពុំឈូក ព្រះអង្គ ស្វេតច្ឆ័ត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវិវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្មែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថ ព្រោះយើងខ្ញុំបានចូលខ្លួនមកសុំធ្វើសម្បថសច្ចាប្រណិធាន ដើម្បីបំពេញតួនាទីជាភ្នាក់ងារនគរបាលយុត្តិធម៌នាពេលនេះ ។

បើយើងខ្ញុំប្រព្រឹត្តល្មើសឃ្លាតឃ្លាតចាកច្បាប់ មិនអនុវត្តត្រឹមត្រូវតាមច្បាប់ ដោយមានចេតនាទុច្ចរិត សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់ បំផ្លាញយើងខ្ញុំឱ្យវិនាសលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ឡានម៉ូតូបុក ខ្លាខាំ ពស់ចឹក លុះអានាគតជាតិ ឱ្យព្រាត់ប្រាស់ និរាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ ។

បើយើងខ្ញុំប្រព្រឹត្តល្អទៀងត្រង់ ត្រឹមត្រូវតាមគន្លងច្បាប់ យកចិត្តទុកដាក់ប្រឹងប្រែងអនុវត្តការងារ ដោយស្មោះត្រង់ អស់ពីចិត្តពីថ្លើម សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យយើងខ្ញុំ មានអាយុវែងយឺនយូរ មានសេចក្តីសុខដុមរមនា មានសុខភាពល្អ មានទ្រព្យសម្បត្តិ មាស ប្រាក់ កែវកង ពិទូរ្យស្វរ្យកាន្ត សម្បូរហូរហៀរ លុះអនាគតជាតិ បានជួបតែសេចក្តីល្អ មានទ្រព្យស្តុកស្តម្ភ កិត្តិយសថ្លៃថ្នូរ ចម្រុងចម្រើន ថ្កុំថ្កើងរុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។



# ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈ ជាភ្នាក់ងារនគរបាលយុត្តិធម៌របស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ជាដរាបតរៀងទៅ ។

# ច្បាប់
# ស្តីពី
# ការទប់ស្កាត់អំពើហិង្សា ក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ

# ព្រះរាជក្រម

នស/រកម/១០០៥/០៣១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ លើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្ដីពី

# ការទប់ស្កាត់អំពើហិង្សា

# ក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ

3/12

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គម នៅព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មានទិសដៅបង្កើតយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី ២
## វិសាលភាពនៃការអនុវត្ត

**មាត្រា ២.-**

អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ :

១-ប្តី ឬ ប្រពន្ធ

២-កូនក្នុងបន្ទុក

៣-ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ ។

**មាត្រា ៣.-**

អំពើហិង្សាក្នុងគ្រួសារ ទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលា និង ប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុតដើម្បីការពារជនរងគ្រោះ ឬ ជនអាចនឹងរងគ្រោះ ។

អំពើហិង្សារួមមាន :

-ការប៉ះពាល់ដល់ជីវិត

-ការប៉ះពាល់ដល់បូរណភាពរូបកាយ

-ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ

-ការឈ្លានពានខាងផ្លូវភេទ ។

**មាត្រា ៤.-**

អំពើប៉ះពាល់ដល់ជីវិត រួមមាន :

-មនុស្សឃាតដោយគិតទុកជាមុន

-មនុស្សឃាតដោយចេតនា

-មនុស្សឃាតដោយអចេតនា បណ្ដាលមកពីអំពើចេតនាផ្សេងទៀតនៃជនល្មើស

-មនុស្សឃាតដោយអចេតនា ។

**មាត្រា ៥.-**

អំពើប៉ះពាល់ដល់បូរណភាពរូបកាយ រួមមាន :

-ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ឬ ឥតអាវុធមានរបួស ឬ គ្មានរបួស

-ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ ។

**មាត្រា ៦.-**

អំពើទារុណកម្ម ឬ អំពើឃោរឃៅ រួមមាន :

-ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ

-ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបកាយដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់ ។

**មាត្រា ៧.-**

អំពើឈ្លានពានខាងផ្លូវភេទ រួមមាន :

-ការប្រើហិង្សាសេពសន្ថវៈ

-ការបៀតបៀនកេរ្តិ៍ខ្មាស

-ការធ្វើអាស្រូវភាស ។

**មាត្រា ៨.-**

ត្រូវទប់ស្កាត់ផងដែរ ចំពោះអំពើគំរាមកំហែងក្នុងគោលបំណងធ្វើឱ្យជនរងគ្រោះភ័យខ្លាច តក់ស្លុត និងអំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិនៃជនដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារតែមួយ ។

មិនរាប់បញ្ចូលថាជាការប្រើហិង្សា ឬ សកម្មភាពហិង្សាក្នុងគ្រួសារទេ រាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មាន ឬ ធ្វើការដាស់តឿនក្រើនរំលឹក ឬ ចាត់វិធានការនានាសមស្របដើម្បីឱ្យសហព័ទ្ធ ឬ កូន ឬ អ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរ និងទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ប្រសិនបើការប្រៀនប្រដៅនិងការអប់រំនោះធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌និងស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## សមត្ថកិច្ច និងនីតិវិធី

**មាត្រា ៩.-**

អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬ បម្រុងនឹងកើតឡើង ដើម្បីទប់ស្កាត់ និងការពារជនរងគ្រោះ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

**មាត្រា ១០.-**

ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មន្ត្រីនៃក្រសួងកិច្ចការនារីបម្រើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់នេះ ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១១.-**

ក្នុងករណីអវត្តមាននៃមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌រួចហើយនោះ មន្ត្រីសមត្ថកិច្ចដទៃទៀតរួមមាន មន្ត្រីនគរបាល ភ្នាក់ងារនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋាន ឃុំ សង្កាត់ មន្ត្រីរបស់ក្រសួងកិច្ចការនារី រួមទាំងមេភូមិដែលបានធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះត្រូវបានទទួលអំណាចពីច្បាប់នេះ ដើម្បីធ្វើកំណត់ហេតុជូនទៅតុលាការ ។ កំណត់ហេតុនេះ មានតម្លៃស្មើគ្នាដូចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ ។

**មាត្រា ១២.-**

ក្នុងការអនុវត្តភារកិច្ច អាជ្ញាធរមានសមត្ថកិច្ចដូចបានចែងក្នុងមាត្រា ៩ មាត្រា ១០ និងមាត្រា ១១ ខាងលើនេះ ត្រូវគោរពតាមនីតិវិធីដែលបានកំណត់ក្នុងបញ្ញត្តិនៃច្បាប់នេះ និងនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៤

## វិធានការទប់ស្កាត់ និងការការពារជនរងគ្រោះ

**មាត្រា ១៣.-**

ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើត ឬ ជឿជាក់ថានឹងកើតឡើង អាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយ:

-ឃាត់ទុកអាវុធ ឬ វត្ថុជាក់ស្តែងដែលជនមុខសញ្ញាបាន ឬ អាចប្រើប្រាស់

-បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬ បង្វែរជនរងគ្រោះ

បើមានការស្នើសុំពីជនរងគ្រោះ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

-ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្នដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់

-ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សាដែលមានចែងនៅក្នុងមាត្រា ២០ និងមាត្រា ២៦ នៃច្បាប់នេះ ។

ជនមុខសញ្ញាក្នុងច្បាប់នេះ គឺសំដៅដល់អ្នកដែលបានប្រព្រឹត្ត កំពុងប្រព្រឹត្តនិងត្រៀមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ។

**មាត្រា ១៥.-**

ដើម្បីការពារសន្តិសុខជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចរដ្ឋបាលស្របតាមមាត្រា ៤៣ មាត្រា ៤៨ និងមាត្រា ៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងចាត់វិធានការបណ្តោះអាសន្នស្របច្បាប់ដែលមានជាអាទិ៍ :

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬ ដោយអ្នកផ្សេង

-ហាមបំផ្លាញទ្រព្យសម្បត្តិ ឬ ណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬ របស់ជនរងគ្រោះ ឬ របស់ញាតិសាលោហិតរបស់ជនរងគ្រោះ

-ហាមជនមុខសញ្ញាចូលទៅជិត ឬ ចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬ កន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច

-ចាត់វិធានការស្របច្បាប់ផ្សេងទៀត ដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងគ្រួសារ ឬជនដែលពាក់ព័ន្ធ ។

ft

**មាត្រា ១៥.-**

បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែងកើតឡើងហើយ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចូលទៅក្នុងទីកន្លែងកើតហេតុ ទោះជាពុំមានដីកាតុលាការអនុញ្ញាតឱ្យចូលក៏ដោយ ក្នុងករណីទាំងឡាយណាដែលមន្ត្រី និងភ្នាក់ងារមានសមត្ថកិច្ច យល់ដោយសមហេតុផលថាមានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងក្នុងអំឡុងពេល ៤៨ម៉ោងកន្លងផុត ឬនឹងអាចកើតឡើងក្នុងអំឡុងពេល ២៤ម៉ោងខាងមុខ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

**មាត្រា ១៦.-**

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឱ្យចេញដីកាការពារ ។

ចៅក្រមដែលទទួលបាត់ការ ត្រូវចេញដីកាការពារដោយមានវត្តមាន ឬ ពុំចាំបាច់មានវត្តមានជនមុខសញ្ញា ។

**មាត្រា ១៧.-**

ក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សា ឬ សម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬ មជ្ឈិមធ្ងន់ធ្ងរបានទេ ។

**មាត្រា ១៨.-**

អាជ្ញាធរមានសមត្ថកិច្ច អាចឃាត់ខ្លួនជនមុខសញ្ញាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬ ជនមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការ ដូចមានចែងក្នុងមាត្រា ២៤ និងមាត្រា ២៥ នៃច្បាប់នេះ ដោយពុំចាំបាច់មានដីកាតុលាការ ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ ការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ចដែលពុំមានដីកាពីតុលាការ ត្រូវហាមឃាត់ ។

ក្នុងករណីអនុវត្តតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុច្បាស់លាស់ កសាងសំណុំរឿង និងបញ្ជូនជនមុខសញ្ញាដែលត្រូវឃាត់ខ្លួនទៅតុលាការជាបន្ទាន់ ក្នុងអំឡុងពេលអតិបរិមាដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីចាត់វិធានការបន្ថែមឱ្យស្របច្បាប់ ។

**មាត្រា ១៩.-**

អំពើហិង្សាក្នុងគ្រួសារណាដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌមានលក្ខណៈជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ទោះអំពើហិង្សានេះបានកន្លងផុតហើយក៏ដោយ ។

បណ្តឹងអាជ្ញា ត្រូវធ្វើឡើងតាមបែបបទដែលមានចែងក្នុងច្បាប់នេះ និងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៥

## សិទ្ធិអំណាចតុលាការ

**មាត្រា ២០.-**

ដីកាការពារមានអនុភាពបង្គាប់បញ្ជាលើជនមុខសញ្ញា លើអាជ្ញាធរមានសមត្ថកិច្ច និងលើជនដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ។ ដីកាការពារនេះ ជាវិធានការផ្នែករដ្ឋប្បវេណី ។

ដីកាការពារមានកម្មវត្ថុចង្អុលបង្ហាញអំពីស្ថានភាព សកម្មភាព ឬអាកប្បកិរិយាទាំងអស់ជាការបង្គាប់ឱ្យធ្វើក្តី ឬ បញ្ជាហាមឃាត់ទង្វើក្តី ដែលទាក់ទិនទៅនឹងតម្រូវការការពារជនរងគ្រោះ ឬ បុគ្គលណាដែលទទួលការគំរាមកំហែងពីអំពើហិង្សាក្នុងគ្រួសារ ។

ដីកាការពារមាន :

១-ឥទ្ធិពលសម្រាប់មួយរយៈ

២-ឥទ្ធិពលបណ្តោះអាសន្នស្របតាមបញ្ញត្តិនៃមាត្រា ២៣ នៃច្បាប់នេះ ។

ចៅក្រមមានសមត្ថកិច្ចមានសិទ្ធិចេញដីកាការពារជាថ្មី ស្របតាមស្ថានភាពជាក់ស្តែង ឬ បទបញ្ញាណាមួយក្នុងលក្ខណៈសមស្រប ។

**មាត្រា ២១.-**

មានតែតុលាការខេត្ត ក្រុងទេ ដែលមានសមត្ថកិច្ចចេញដីកាការពារជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារលើគ្រប់ករណីទាំងអស់ ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងផ្ទួនគ្នាជាផ្នែកស៊ីវិលក្តី ជាផ្នែករដ្ឋបាលក្តី ឬ ជាផ្នែកព្រហ្មទណ្ឌក្តី ។

**មាត្រា ២២.-**

ពាក្យបណ្តឹងសុំដីកាការពារពីតុលាការអាចធ្វើឡើងដោយ :

១-ជនរងគ្រោះ ឬ តំណាងជនរងគ្រោះ ឬ អាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬ មន្ត្រី ភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ ។

២-ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនពិការចលចរិត ឬ ជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន ។

**មាត្រា ២៣.-**

ដីកាការពារមានពីរដំណាក់កាល :

១-ដំណាក់កាលទី ១ ហៅថាដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល ២(ពីរ)ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ ។

២-ដំណាក់កាលទី ២ ហៅថាដីកាការពារមានរយៈពេល ៦(ប្រាំមួយ)ខែ ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬ មុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៤.-**

តុលាការអាចចេញដីកាការពារបណ្តោះអាសន្ន នៅពេលទទួលបណ្តឹងការពារ

ភ

ដោយមិនចាំបាច់សាកសួរជនមុខសញ្ញា បើសិនវិធានការបណ្តោះអាសន្ននោះមានភាពចាំបាច់សម្រាប់រក្សាការពារសុវត្ថិភាពនិងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៥.-**

ក្នុងការចេញដីកាការពារ តុលាការមានសិទ្ធិកំណត់បញ្ហាលើសកម្មភាពជនមុខសញ្ញា ដើម្បីការពារជនរងគ្រោះដូចតទៅ :

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬ ដោយអ្នកផ្សេង

-ហាមចូលទៅជិត ឬ ចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬ កន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះនិងអាជ្ញាធរមានសមត្ថកិច្ច ។

-ហាមជនមុខសញ្ញាទាក់ទងជាមួយជនរងគ្រោះតាមផ្លូវណាមួយ

-ហាមបំផ្លាញទ្រព្យ ឬ ចាត់ចែងលក់ទ្រព្យរបស់ជនរងគ្រោះឬញាតិសាលោហិតរបស់ជនរងគ្រោះ

-បំបែកជនមុខសញ្ញាពីលំនៅឋានរួម ឬ បំបែកជនរងគ្រោះ បើមានការស្នើសុំ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

បើយល់ថាជាការចាំបាច់សម្រាប់ការពារ ឬ រៀបចំសុវត្ថិភាព សុខភាព និងសុខុមាលភាពជនរងគ្រោះ តុលាការអាចបង្គាប់ដោយចាត់វិធានការបន្ថែមទៀតដូចតទៅ :

-បញ្ជាឱ្យភ្នាក់ងារនគរបាល ឬ កងរាជអាវុធហត្ថណាម្នាក់ការពារបេតិកភណ្ឌផ្ទាល់ខ្លួនរបស់ជនរងគ្រោះ

-សម្រេចអំពីការថែរក្សាកូន និងអំពីសិទ្ធិទៅសួរសុខទុក្ខកូន ដោយគិតយ៉ាងខ្ពស់បំផុតពីសិទ្ធិ និងផលប្រយោជន៍នៃកុមារនោះ

-បញ្ឈប់កាតព្វកិច្ចហិរញ្ញវត្ថុនៃជនរងគ្រោះចំពោះជនមុខសញ្ញា

ᯤ

-កំហិតឱ្យជនមុខសញ្ញាផ្តល់ជំនួយហិរញ្ញវត្ថុឱ្យជនរងគ្រោះដោយផ្អែកតាមលទ្ធភាពធនធាននៃជនមុខសញ្ញា ។

**មាត្រា ២៦.-**

ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬ ផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬ បទលហុ ការផ្សះផ្សា ឬ សម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង ។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាលដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៧.-**

អនុលោមលើខ្លឹមសារនៃមាត្រា ២៥ ខាងលើ តុលាការត្រូវព្យាយាមធ្វើការផ្សះផ្សាភាគីមានវិបត្តិអំពើហិង្សា ក្នុងលក្ខខណ្ឌឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់សមាជិកនៃគ្រួសារនោះ ។ ក្នុងការផ្សះផ្សាសម្រុះសម្រួលគ្នា តុលាការត្រូវចៀសវាងធ្វើសម្ពាធលើគូភាគីដែលមិនព្រមស្រុះស្រួលគ្នា ឬបង្ខិតបង្ខំភាគីណាមួយឱ្យចូលផ្សះផ្សា ឬ បង្ខិតបង្ខំឱ្យចុះកិច្ចព្រមព្រៀងដោយគ្មានការព្រមព្រៀងពីភាគីទាំងពីរឡើយ ។

**មាត្រា ២៨.-**

ក្នុងករណីអំពើហិង្សាពាក់ព័ន្ធដល់កុមារ អាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីទទួលបន្ទុកបម្រើប្រយោជន៍កុមារនិងការពារសុខុមាលភាពកុមារ ធ្វើការតាមដានបញ្ហានេះ ។ ក្នុងករណីធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងទៅតុលាការ ។

អ្នកទទួលខុសត្រូវណាម្នាក់ដែលតុលាការបានបង្គាប់រួមទាំងព្រះរាជអាជ្ញាផង ត្រូវទទួលបន្ទុកតាមដានអំពីស្ថានភាពនៃកុមារ និងធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនេះជូនទៅតុលាការ ។

តុលាការអាចផ្តល់អាណត្តិដល់ស្ថាប័នមានសមត្ថកិច្ច ដើម្បីរកជំនួយនិងការគាំទ្រជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារព្រមទាំងការពារសុវត្ថិភាពនិងសុខុមាលភាពជនរងគ្រោះ ពេលតុលាការកំពុងបំពេញនីតិវិធី ។

**មាត្រា ២៩.–**

លើកលែងតែករណីបន្ទាន់ដូចមានចែងក្នុងមាត្រា ២៣ តុលាការត្រូវជូនដំណឹងទៅជនមុខសញ្ញាអំពីការស្នើសុំដីកាការពារមិនឱ្យលើសពី ៥(ប្រាំ)ថ្ងៃ មុននឹងយកបញ្ហានេះមកពិនិត្យ ។ បើជនមុខសញ្ញានេះមិនបង្ហាញខ្លួននៅមុខតុលាការ ដើម្បីបញ្ជាក់អំពីហេតុផល តុលាការអាចពិនិត្យបញ្ហាដោយពុំមានវត្តមានជនមុខសញ្ញា ឬ បើជាការចាំបាច់ អាចចាត់វិធានការតាមនីតិវិធីជាធរមាន ចំពោះជនមុខសញ្ញាដែលមិនអើពើនឹងសេចក្តីសម្រេចរបស់តុលាការ ។

ក្នុងករណីអវត្តមាន ឬ ការមិនអើពើរបស់ជនមុខសញ្ញាអំពីសេចក្តីសម្រេចរបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវស្នើតុលាការចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣០.–**

បើមានសំណើពីភាគីណាមួយ តុលាការអាចកែប្រែ លុបចេញ ឬ បន្ថែមទម្ងន់នៅក្នុងដីកាការពារក្រោយពីបានជូនដំណឹងទៅភាគីម្ខាងទៀត ៥(ប្រាំ)ថ្ងៃ មុននឹងសម្រេច ។

គូភាគីអាចធ្វើការតវ៉ាឱ្យតុលាការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ២(ពីរ)ខែ ចាប់ពីថ្ងៃចេញដីកាការពារ ។

**មាត្រា ៣១.–**

ជនរងគ្រោះ និងជនមុខសញ្ញាមានសិទ្ធិទទួលអ្នកការពារតាមផ្លូវច្បាប់ ឬមានសិទ្ធិជ្រើសរើសអ្នកតំណាងដែលខ្លួនទុកចិត្ត នៅគ្រប់ដំណាក់កាលនៃនីតិវិធី ។

**មាត្រា ៣២.-**

ក្រោយពីបានចេញដីកាការពាររួចហើយ ព្រះរាជអាជ្ញា ឬ មន្ត្រីមានសមត្ថកិច្ចដែលច្បាប់ប្រគល់ឱ្យត្រូវចាត់គ្រប់វិធានការ ដើម្បីអនុវត្តដីកាការពារតាមនីតិវិធីកំណត់។

## ជំពូកទី ៦
## ការអប់រំ ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល

**មាត្រា ៣៣.-**

រដ្ឋ ត្រូវយកចិត្តទុកដាក់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទូទាំងប្រទេសបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិនៃច្បាប់នេះ ជាពិសេសអំពីការទទួលខុសត្រូវក្នុងគ្រួសារ ការគោរពសិទ្ធិគ្នាទៅវិញទៅមកដើម្បីលើកស្ទួយតម្លៃគ្រួសារខ្មែរ សីលធម៌ សុជីវធម៌ ការរស់នៅ ការថែរក្សា និងការអប់រំគ្រួសារ របៀបដោះស្រាយទំនាស់ដោយអហិង្សា និងសន្តិវិធី ព្រមទាំងណែនាំឱ្យយល់ពីវិធានការទាំងឡាយក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារដល់ជនរងគ្រោះ ។

រដ្ឋជំរុញភាគីដែលមានវិបត្តិអំពើហិង្សាក្នុងគ្រួសារឱ្យចូលរួមក្នុងវគ្គពិគ្រោះបញ្ហា ដើម្បីរៀនសូត្រស្វែងយល់អំពីវិធីសាស្ត្រនានា ក្នុងការដោះស្រាយទំនាស់ និងអប់រំដោយមិនប្រើប្រាស់អំពើហិង្សា ។

**មាត្រា ៣៤.-**

ក្រសួង ស្ថាប័នទាំងឡាយរបស់រដ្ឋត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន អង្គការនានា និងផ្នែកឯកជន ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយនិងអប់រំប្រជាពលរដ្ឋអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

មន្ត្រីពាក់ព័ន្ធទាំងឡាយ និងភ្នាក់ងារអង្គការនានាត្រូវបានទទួលការបណ្តុះបណ្តាលអំពីបញ្ហានៃអំពើហិង្សាក្នុងគ្រួសារ និងវិធានការទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ ដើម្បីឱ្យយល់ពីមូលហេតុចម្បងនានាដែលបង្កឱ្យមានការកើតឡើងនូវអំពើហិង្សាក្នុងគ្រួសារ និងបទល្មើសទាំងឡាយដែលពាក់ព័ន្ធវិស័យនេះ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.–**

អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣៦.–**

ការរះចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬ បទលហុ ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០៥

នស.០៥១០.៤៣៤ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**ហត្ថលេខា**

**អ៊ឹង កន្ថាផាវី**

លេខ ៤៥៤ ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

១៥/៤/៦

# ច្បាប់
# ស្តីពីព្រៃឈើ

**មាត្រា ៧៥.-**

បុគ្គលដែលប្រមូលផលដឹកជញ្ជូន កែច្នៃ សន្និធិ លក់ដូរ ឬនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវទទួលខុសត្រូវ ក្នុងការបង្ហាញឯកសារដើមស្របច្បាប់នៃផល អនុផលព្រៃឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រួតពិនិត្យ ។

## ជំពូកទី ១៤
## នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

**មាត្រា ៧៦.-**

បទល្មើសព្រៃឈើ ជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចមានចែងក្នុងច្បាប់នេះ ។ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ ។

ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងវង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៧៧.-**

នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ។

មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានលុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.–**

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយនិងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួល និងជួយផ្ដល់កំលាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ឬថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្ដោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

ក្នុងករណីដែលអាជ្ញាធរទាំងឡាយបានជួបប្រទះនូវបទល្មើសព្រៃឈើជាក់ស្ដែង អាជ្ញាធរទាំងនោះ :

១- ត្រូវជូនពត៌មានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលនៅជិតបំផុត ។

២- អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និងចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្ដោះអាសន្ន រួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី ។

៣- មិនត្រូវប្រមូលប្រាក់ពិន័យ ឬរឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ ។

**មាត្រា ៧៩.–**

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិ ដូចតទៅ :

១- អាចឱ្យបុគ្គលណាមួយឆ្លើយតបសំណួរនិងផ្ដល់ពត៌មានដែលពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ ។

២- ចូលធ្វើការត្រួតពិនិត្យ ឬឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើង ក្នុងករណីបទល្មើសជាក់ស្ដែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ។

៣- ដកហូតជាបណ្ដោះអាសន្ននូវអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះ បើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិចូលឆែកឆេរនៅក្នុងទីធ្លា អាគារ ឬក្នុងលំនៅឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ ។ ការឆែកឆេរត្រូវធ្វើចំពោះមុខជនជាប់សង្ស័យនិងមានសាក្សីពីរ (២)នាក់ដែលជាអ្នកជិតខាង ឬអ្នកម្ចាស់ផ្ទះ ។

**មាត្រា ៨០.-**

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងត្រូវចាប់ឃាត់ជាបណ្តោះអាសន្ន :

១- រាល់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២- សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញធនធានព្រៃឈើ ។

៣- គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើនិងសត្វព្រៃ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់ ៤៨ ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ។

**មាត្រា ៨១.-**

ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ ។

**មាត្រា ៨២.-**

វត្ថុតាងនៃបទល្មើសព្រៃឈើ ត្រូវបានកំណត់ដូចខាងក្រោម :

១- ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដ នៃបទល្មើស ។

២- សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

វត្ថុតាងដូចមានចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើនេះ ត្រូវឃាត់ទុកជាបណ្ដោះអាសន្ន រហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ពិន័យអន្តរការណ៍ ឬតាមការជំនុំជំរះរបស់តុលាការ ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលព្រៃឈើល្មើស ឬផលប្រមាញ់ល្មើស អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលគ្មានម្ចាស់នៅជាមួយត្រូវឃាត់ខ្លួនជាបណ្ដោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើសនិងអ្នកសមគំនិត ។

ផលប្រមាញ់ស្រស់ជាអាទិ៍ សត្វរស់ និងសំណាកសត្វព្រៃដែលបានឃាត់ទុកហើយងាយខូចខាត ផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិលែង ឬបំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ។

**មាត្រា ៨៣.–**

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និងពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ ។

**មាត្រា ៨៤.–**

នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធទៅក្នុងសំណុំរឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ ។

**មាត្រា ៨៥.–**

អាជ្ញាយុកាលនៃបណ្ដឹងបទល្មើសព្រៃឈើមាន :

១- បទល្មើសព្រៃឈើថ្នាក់ទី ១ មានអាជ្ញាយុកាលដប់ប្រាំ (១៥)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

២- បទល្មើសព្រៃឈើថ្នាក់ទី ២ មានអាជ្ញាយុកាលប្រាំ (៥)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

៣- បទល្មើសព្រៃឈើថ្នាក់ទី ៣ មានអាជ្ញាយុកាលមួយ(១)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

ការអនុវត្តន៍អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើ ត្រូវស្របតាមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៨៦.–**

បុគ្គលដែលប្រព្រឹត្តបទល្មើសព្រៃឈើដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ។

បុគ្គលជាភ្នាក់ងារនៃអង្គភាពរដ្ឋ ឬឯកជនដែលប្រើប្រាស់មធ្យោបាយរបស់អង្គភាពដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ បុគ្គល ឬប្រធានអង្គភាពនោះ ត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

បទល្មើសព្រៃឈើដែលប្រព្រឹត្តឡើងដោយបុគ្គលឬក្រុម ក្រោមការចាត់តាំងរបស់អង្គភាពណាមួយ ប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨៧.–**

រូបវន្តបុគ្គលបរទេស ឬនីតិបុគ្គលបរទេសដែលបានប្រព្រឹត្តបទល្មើសព្រៃឈើត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨៨.–**

មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចមានសិទ្ធិអំណាចផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូលឬមួយផ្នែក មួយរយៈ ដើម្បីចាត់ការតាមនីតិវិធីក្នុងករណីព្រៃសម្បទានិកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬល្មើសនឹងកិច្ចព្រមព្រៀងព្រៃសម្បទានរហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់ ។

**មាត្រា ៨៩.–**

បុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចណាមួយ ធ្វើឡើងដោយរដ្ឋបាលព្រៃឈើស្របតាមច្បាប់នេះ មានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលសេចក្តីសម្រេចនេះមកប្រធានរដ្ឋបាលព្រៃឈើ។

ប្រធានរដ្ឋបាលព្រៃឈើត្រូវសម្រេចលើបណ្តឹងតវ៉ានោះ ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរ ។ ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញ

ដោយប្រធានរដ្ឋបាលព្រៃឈើ ក្នុងករណីមិនអាចទទួលយកបាន ជននោះអាចធ្វើបណ្តឹងតវ៉ាទៅតុលាការ ។

ការតវ៉ាក្រោមមាត្រានេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាចនិងដំណើរការអនុវត្តន៍ច្បាប់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។

## ជំពូកទី ១៥
## បទល្មើសព្រៃឈើ និងទោសប្បញ្ញត្តិ

### មាត្រា ៩០.–

ទណ្ឌកម្មក្នុងបទល្មើសព្រៃឈើមាន : ទោសជាប់ពន្ធនាគារ រឹបអូសវត្ថុតាង ពិន័យដោយតុលាការ ពិន័យអន្តរការណ៍ ការផ្តួសផុលការខូចខាត ការព្រមាន ការដកហូត ឬការល្បរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ការផ្តួសផុលការខូចខាត និងការព្រមានជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬផ្តួសផុលការខូចខាត រដ្ឋបាលព្រៃឈើអាចបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ ។

ចំពោះមន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសទណ្ឌដែលកំណត់ក្នុងច្បាប់នេះ ។

### មាត្រា ៩១.–

រដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ដូចមានចែងក្នុងមាត្រា ៩៦ នៃច្បាប់នេះ ។ ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើអាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិនឱ្យលើសពីដប់ប្រាំ (១៥)ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច ។

បែបបទ និងសិទ្ធិសម្រេចពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ :

១- ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស ។

២- ការខូចខាតដល់បរិស្ថាន ។

៣- ចំនួននៃការប្រព្រឹត្តល្មើស ។

៤- បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល ។

៥- ការប្រព្រឹត្តល្មើសដោយចេតនា ។

**មាត្រា ៩២.-**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រមតុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាង ត្រូវបង់ចូលថវិកាជាតិ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសព្រៃឈើជាក់លាក់ណាមួយ ។

**មាត្រា ៩៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំ ទៅដប់ (១០)ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ។

២- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ២ ត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និង/ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០)រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៣- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ៣ ត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ (១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៤- ការព្រមាន ការផ្តួសផុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការល្បួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីអនុវត្តនឹងគភាពទូទាំងប្រទេស ។

**មាត្រា ៩៤.–**

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬផ្តូសផ្តុលការខូចខាតឱ្យមានលក្ខខណ្ឌដូចដើមឡើងវិញ ។

**មាត្រា ៩៥.–**

រដ្ឋបាលព្រៃឈើអាចចេញលិខិតព្រមាន និងតម្រូវឱ្យផ្តូសផ្តុលការខូចខាតចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម ៖

១- ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចំការឈើ ឬថ្នាលកូនឈើរបស់រដ្ឋ ដោយបំផ្លាញឈើ ឬកូនឈើនៅទីនោះ ។

២- ធ្វើឱ្យរបួស ឬធ្វើឱ្យខូចខាតដល់ដើមឈើ ឬរុក្ខជាតិផ្សេងទៀតដែលកំពុងថែរក្សា ឬដែលបានដាំ ។

៣- លួច ឬធ្វើឱ្យខូចខាតដល់របង បង្គោល ឬស្លាកសញ្ញាក្នុងថ្នាលបណ្តុះកូនឈើ ឬក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

**មាត្រា ៩៦.–**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ (២)ទៅ បី(៣)ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

១- កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ ។

២- ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៣- ធ្វើសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៤- ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅលើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន។

៥- ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព ។

៦- មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៧- ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត ។

៨- នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និងប្រភេទរុក្ខជាតិព្រៃដែលលើសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ ។

៩- កាប់រំលំ អារ ច្រៀក និងចាំងឈើមូលក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬប្រើរណារយន្តជាមធ្យោបាយ ប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសញ្ញា ។

១០- ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត ។

១១- ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬប្រមូលយកមកដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១២- ផល អនុផលព្រៃឈើដែលយកមកកែច្នៃ ត្រូវបានកាប់ ឬប្រមូលដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៣- ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយបានមកពីការកាប់ ឬរុករក ដឹកជញ្ជូន កែច្នៃដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៤- ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៥- នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ ។

១៦- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ។

១៧- យកធ្វើជាកម្មសិទ្ធ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយកម្រ ។

១៨- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមមានដោយកម្រ ។

១៩- ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយបង្គួរ ដោយគ្មានលិខិតអនុញ្ញាត ។

២០- បរបាញ់ក្នុងទីសាធារណៈ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ នៃមាត្រានេះ មិនរាងចាលក្នុងរយៈពេលមួយ (១)ខែ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ(២)ទៅបួន(៤)ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ។

វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើ ត្រូវរឹបអូសជាសម្បត្តិរដ្ឋស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ វត្ថុតាងផ្សេងទៀតក្រៅពីផល អនុផលព្រៃឈើ អាចប្រគល់ឱ្យសាមីជនវិញតែក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា ៩៦ នៃច្បាប់នេះ។

**មាត្រា ៩៧.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំ ទៅដប់ (១០)ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ដកហូតកិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងកំទេចចោលវត្ថុតាងក្លែង ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១- ក្លែងញញួរត្រា ឬប្រើញញួរត្រាក្លែង ឬបំផ្លាញស្លាកញញួរត្រារដ្ឋបាលព្រៃឈើដែលវាយលើឈើហុប ។

២- ក្លែងបន្លំដោយស្មៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ឬពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ។

៣- ក្លែងបន្លំលិខិតសាធារណៈដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ឬសត្វព្រៃ។

៤- កំផ្លាញ ពកក់ពាំង ពកេ ឬលួចវត្ថុតាងព្រៃពេភី ។

៥- កំទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតដល់ព្រំសីមានៃតំបន់ព្រៃឈើ ។

៦- កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ។

៧- បង្កឱ្យភ្លើងឆេះព្រៃដោយចេតនា ។

៨- គ្រៀវ បំពុល កាប់បំផ្លាញ ឆ្លូលវិលំដើមឈើ ឬគាស់រំលើងប្រមូលគល់ឈើ ។

៩- បង្កើតមូលដ្ឋានកែច្នៃរលឿរមៀត ឬមូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំផ្លាញព្រៃឈើនិងមជ្ឈដ្ឋានព្រៃឈើ ។

១០- បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមជិតផុតពូជ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ១ មិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសព្រៃឈើថ្នាក់ទី ១ នៃច្បាប់នេះ ។

**មាត្រា ៩៨.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១- មិនគោរពតាមបទបញ្ញាបច្ចេកទេសដែលបានកំណត់ក្នុងក្រមបច្ចេក-ទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។

២- មិនគោរពផែនការគ្រប់គ្រង និងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣- យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ ។

៤- ប្រើប្រាស់គ្រឿងចក្រ យានយន្តបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសំគាល់ ។

៥- គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

៦- ប្រើប្រាស់ដីព្រៃឈើលើសពីទំហំអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាត ដើម្បីស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃឈើ ឬដាក់តាំងមូលដ្ឋានសំណង់ ឬលំនៅដ្ឋានគ្រប់ប្រភេទតាមផងផ្លូវ ។

៧- បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ប្រភេទធំ និងមធ្យមដោយគ្មានប្រកាស ។

៨- បង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដោយគ្មានលិខិតអនុញ្ញាត ។

៩- បរបាញ់ក្នុងរដូវកាលហាមឃាត់ឬក្នុងតំបន់ការពារ ។

១០- បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមមានដោយកម្រ ។

១១- បរបាញ់សត្វព្រៃដោយប្រើមធ្យោបាយដែលបង្កគ្រោះថ្នាក់ដល់ជីវ-សាស្ត្រសត្វ ។

១២- យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលប្រភេទសត្វរស់ និងសំណាកក្នុងក្រុមជិតផុតពូជ ។

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន(១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១- ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

២- ប្រមូលផល អនុផលព្រៃឈើក្រៅផែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬក្រៅភូមិសាស្ត្រដែលកំណត់ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣- ផ្ទេរសិទ្ធិ ឬលក់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៤- កាប់ដើមឈើក្នុងចំការដាំឈើរបស់រដ្ឋ ។

៥- ប្រមូលផល អនុផលព្រៃឈើ ចំពោះប្រភេទឈើជាប់លិដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ ប្រភេទឈើដែលមានដោយកម្រ ប្រភេទឈើដែលប្រជាជនចោះយកជ័រតាមប្រពៃណីនិងប្រភេទឈើផ្តល់ជ័រមានតម្លៃ ។

៦- នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ដោយគ្មានទិដ្ឋាការពីអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ និងគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧- នាំចេញផល អនុផលព្រៃឈើដែលគ្មានអាជ្ញាប័ណ្ណ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ២ មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ១ នៃច្បាប់នេះ ។

**មាត្រា *៩៩*.–**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ៣ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ (១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០)រៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ

ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :

១- ប្រើប្រាស់វណារយន្តគ្រប់ប្រភេទដែលបំពីការប្រមូលផល អនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

២- នាំចូលគ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទសម្រាប់ការប្រមូលផល អនុផលព្រៃឈើ ដោយគ្មានការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣- នាំចេញផល អនុផលព្រៃឈើដែលគ្មានសំណាបិទភ្ជិតរបស់រដ្ឋបាលព្រៃឈើលើខ្លួនថៃនណី ។

៤- យាយី ធ្វើឱ្យរបួស ប្រមូលពង កូន នៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬក្រុមមានដោយកម្រ ឬបំផ្លាញជម្រករបស់វា ។

៥- បង្កើតរោងសន្និធិ លក់ដុំ រាយ នូវផល អនុផលព្រៃឈើនិងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ដោយគ្មានលិខិតអនុញ្ញាត ឬផ្ទុយពីការកំណត់ ។

៦- បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬមិនប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬជាប្រភពថាមពលខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ៣ មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ នៃច្បាប់នេះ ។

**មាត្រា ១០០.-**

សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តរាគមន៍ ផ្តល់ការអនុញ្ញាតដោយផ្ទាល់ឬដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និងធ្វើសកម្មភាពគ្រប់យ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬរាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០)រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល ។

**មាត្រា ១០១.–**

ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល ៖

១- ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២- ចូលរួមទាំងស្រុង ឬដោយផ្នែក និងដោយផ្ទាល់ ក្នុងសកម្មភាពណាមួយនៃអាជីវកម្មព្រៃឈើដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

៣- អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ ។

៤- ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬធ្វើជានិយោជិក ឬអ្នកធានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ (១)ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ ។

៥- មិនបានរាយការណ៍ ឬមិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលបានកើតក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។

៦- ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ពត៌មានឬរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី ១ ។

## ជំពូកទី ១៦

## ការអនុវត្តន៍សាលក្រមតុលាការ

**មាត្រា ១០២.–**

ការអនុវត្តន៍សាលក្រម ឬសាលដីកាស្ថាពរនៃបទល្មើសព្រៃឈើ ជាភារកិច្ចរបស់រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចលើកលែងតែទោសដាក់ពន្ធនាគារ ។

**មាត្រា ១០៣.–**

រាល់សម្រង់សាលក្រម ឬសាលដីកានៃបទល្មើសព្រៃឈើត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

**មាត្រា ១០៤.-**

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរ វត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលព្រៃឈើ ។

## ជំពូកទី ១៧
## អន្តរប្បញ្ញត្តិ

**មាត្រា ១០៥.-**

ព្រៃសម្បទានទាំងឡាយ ទោះជាមានស្រាប់នៅមុនពេលច្បាប់នេះចូលជាធរមានក្តី ឬបានផ្តល់ឱ្យក្រោយៗមកទៀត តាមការដាក់ឱ្យដេញថ្លៃជាសាធារណៈដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះក្តី ព្រៃសម្បទានិកត្រូវចុះកិច្ចព្រមព្រៀងព្រៃសម្បទានតាមគំរូថ្មីតែមួយជាមូលដ្ឋាន ។

**មាត្រា ១០៦.-**

នៅទីណាដែលរដ្ឋបាលព្រៃឈើមានភស្តុតាងបញ្ជាក់ថា ការកាន់កាប់ដីព្រៃណាមួយបានមកពីការកាប់រានដីព្រៃឈើរដ្ឋដោយខុសច្បាប់មុនច្បាប់នេះចូលជាធរមាន រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតជូនដំណឹងក្នុងនាមរាជរដ្ឋាភិបាលជាម្ចាស់កម្មសិទ្ធិលើដីព្រៃឈើរដ្ឋដោយធ្វើការបណ្តេញ និងទាមទារកម្មសិទ្ធិដីព្រៃឈើរដ្ឋមកវិញដោយឥតលក្ខខណ្ឌ ។

**មាត្រា ១០៧.-**

នៅពេលច្បាប់នេះចូលជាធរមាន រោងចក្រ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងឡាយដែលបានបង្កើតឡើង និងកំពុងដំណើរការក្រោមប្រកាសអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងនោះ ត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពរហូតដល់ផុតសុពលភាពនៃប្រកាស ។

ចំពោះរោងចក្រកែច្នៃផល អនុផលព្រៃឈើត្រូវបំពេញបែបបទសុំបន្តផលិតកម្មអាជីវកម្មស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ក្នុងរយៈពេលប្រាំមួយ (៦)ខែ គិតពីច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ១៨
## អវសានប្បញ្ញត្តិ

**មាត្រា ១០៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០៩.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ភ្នំពេញ,ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាព្រះរាជក្រឹត្យបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

ពរ.ល.០២.០៨.០០២៧២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ហត្ថលេខា**

**ចាន់ សារុន**

លេខ: ១៨២៥.ល

ដើម្បីចម្លងចែក

ភ្នំពេញ,ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០០២

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ហត្ថលេខា និង ត្រា**

**ស៊ុន សារី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ

# សញ្ញាបត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ៩២១ ឈ.ស របស់អគ្គស្នងការដ្ឋាននគរបាលជាតិ. ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីមន្ត្រីនគរបាល ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦០ និងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : ................ កើតថ្ងៃទី ........ ខែ ........ ឆ្នាំ ........

ឋានន្តរស័ក្តិ ................ អត្តលេខ ................ ឋានៈ ................

អង្គភាព : នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល សញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : ................

នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

លេខ: ន.ប.យ.ន

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អង្គ_វង្សវឌ្ឍានា

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

---

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌

# សញ្ញាបត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ២៥៤៦/២០១១ ស-ណ របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ស្តីពីមន្ត្រីកងរាជអាវុធហត្ថ ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : លោក ម៉ាំង សុខលុច កើតថ្ងៃទី 0៥ ខែ កក្កដា ឆ្នាំ ១៩៨០

ឋានន្តរស័ក្តិ ឧសេនីយ៍ត្រី អត្តលេខ ១០៨ ៣៦៥ មុខតំណែង ជំនួយការ ការិយាល័យសន្តិសុខ

អង្គភាព : មន្ទីរព័ត៌មាន និងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : លោកឧសេនីយ៍ត្រី ម៉ាំង សុខលុច នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការពារជាតិ
ទាហានឧត្តមសេនីយ៍.ទៀ_បាញ់

លេខ ០៧៣៩/១១ ន.ប.យ.ន.អ.ឃ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អង្គ_វង្សវឌ្ឍានា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រ

## វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី ១៦

បញ្ជាក់ថា : លោកវរសេនីយ៍ត្រី ម៉ាំង សុខលុច អត្តលេខ ១០៨ ៣៦៥

តួនាទីជំនួយការការិយាល័យសន្តិសុខ អ.ហ រាជធានី

បានបញ្ចប់ : វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ជំនាន់ទី ១៦

ពីថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១១ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

ភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

មេបញ្ជាការ

លេខ: ៣៩ /ស.ស.រ.
/២០១១

នាយឧត្តមសេនីយ៍ សៅ សុខា

---

ក្រសួងមហាផ្ទៃ
សាលាភូមិន្ទនគរបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្របញ្ជាក់ការសិក្សា

នាយកសាលាភូមិន្ទនគរបាល

## CERTIFICAT DE SCOLARITE

**Le Directeur de l'Ecole Royale de Police**

បញ្ជាក់ថា:.................................................កើតថ្ងៃទី.......................................នៅ...................ភ្នំពេញ...................

**Certifie que**.................................................**né(e)le**.......................................**à**...................Phnom Penh...................

បានរៀនចប់វគ្គ..........បណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌..........និទ្ទេស..........................នៅសាលាភូមិន្ទនគរបាល

**a suivi le starge**..........Classe de formation des Policiers Judiciers.......... **Mention**..........................**à l'Ecole Royale de police**

ចាប់ពីថ្ងៃទី...២០....ខែ.....មិថុនា......ឆ្នាំ២០០៧....ដល់ថ្ងៃទី..២២....ខែ......មិថុនា.....ឆ្នាំ២០០៧.....។

**du**..........................20 June 2007.......................... **au**..........................22 June 2007..........................

វិញ្ញាបនប័ត្រនេះត្រូវបានចេញឱ្យសាមីជនដើម្បីប្រើប្រាស់ តាមការដែលអាចប្រើបាន។

**Le présent certificat lui est délivré pour servir et valoir ce que de droit.**

រាជធានីភ្នំពេញ. ថ្ងៃទី..២០.....ខែ.មិថុនា...ឆ្នាំ២០០៧.

លេខ:........................

**Phnom Penh, le**........................................

នាយកសាលាភូមិន្ទនគរបាល

**Le directeur de l'Ecole Royale de Police**

ឧត្តមសេនីយ៍ឯក ញ៉ា លឿន